# សម្ភាសន៍ជាមួយឈ្មោះ សាក់ ធួក ភេទស្រី អាយុ៥១ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ កងចល័ត

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅស្រុកមង្គលបូរី ខេត្តបាត់ដំបង

សព្វថ្ងៃរស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០១:១៩:០០

៣៧ទំព័រ

ឈុនលី ៖ និយាយថា ការកកើតស្រុកម៉ាឡៃដំបូង មីងដឹងថាពីដំបូងមកគេហៅតំបន់អី?

ធួក ៖ ដូចអ៊ំនៅនេះ យើងនៅក្នុងរបបប្រជាជន យើងដូចជាមិនសូវដឹងបើគេក្រុមអីទៅគេដឹង ដូចថាគេមេក្រុមគេដឹង ដល់យើង ។

ឈុនលី ៖ គេមកមើលទីតាំងមុនៗអ៊ំ នឹងមកនឹង?

ធួក ៖ ហ្នឹងហើយ គេមើលនឹងឯង ប៉ុនដូចអ៊ំវាកូន ប្រពន្ធទាហានហើយ តែយើងវានៅកូនទេ ដល់ចឹងយើងអត់សូវដឹងយ៉ាងម៉េចទេ គេយកមកយើងមក ។ ហើយអ៊ំមកមុនដំបូង ស្មានតែទៅក្នុងទេ មកពីដីថៃ ស្មានតែទៅក្នុង អត់ដឹងថាគេយកមកទុកនេះទេ ។

ឈុនលី ៖ អានឹងឆ្នាំណា ដែលអ៊ំចេញពីដីថៃមក?

ធួក ៖ ហ្នឹងកាលនឹង៩៣ ពួកអ៊ុនតាក់ចូលមក ។

ឈុនលី ៖ ចឹងខ្ញុំអ៊ុនតាក់ចូលមកនឹង អ៊ំទើបនឹងចេញពីថៃមក?

ធួក ៖ អឺ! ៩៣ ។

ឈុនលី ៖ អានឹងបាននឹងន័យថាចេញមកក្រោយគេប៉ុកម៉េច?

ធួក ៖ ទេ! កាលនោះគេអ្នកពីជំរំគេមិនដឹកទៅក្នុង ។ មែនទេ?

ឈុនលី ៖ ចា៎!

ធួក ៖ ដល់ពេលអ្នកគេខ្មែរក្រហមគេមិនយកមកពីដីថៃដែរ តែគេមិនទៅក្នុងទេ គេដាក់តាមព្រំដែនវិញ ។ ពីព្រោះយើងនៅក្នុងខ្មែរក្រហម យើងមិនទាន់បានទៅក្នុងទេ ពីព្រោះយើងសម័យ

នឹងវាមិនដូចថាចូលលាយចូលគ្នាទាំងអស់ មិនដឹងថាអ្នកដឹកនាំយើងនឹងនៅមានខ្មែរក្រហមទៀតអត់ ។ ដល់ចឹងយើងអត់បានទៅទេ បើនិយាយទៅគឺយើងក៏នៅខ្មែរក្រហមដដែល ។

ឈុនលី ៖ ចុះដើមហេតុដំបូងមកនឹង អ៊ំមកនៅនេះជាមួយអ្នកណាខ្លះមានបងប្អូនឪពុកម្តាយមក?

ធួក ៖ ទេ! គ្មានទេ មានតែយើងជុំប្តីជុំកូនគេក៏មានប្តីមានកូនចឹងទៅចេះតែមក ។

ឈុនលី ៖ ចឹងអ៊ំការឆ្នាំណា?

ធួក ៖ ៨២ ។

ឈុនលី ៖ ៨២?

ធួក ៖ អឺ!

ឈុនលី ៖ បានន័យថាមកដល់ទឹកដីនេះទៅហើយ?

ធួក ៖ មកហើយ មក ។

ឈុនលី ៖ ចុះមកដំបូង ពេលពីដំបូងមក?

ធួក ៖ មិនដំបូងប៉ុន្មានទេ ពីព្រោះ ។

ឈុនលី ៖ អត់ទេ ដូចឆ្នាំ៧៩ដែលគេរត់ពីក្នុងមក?

ធួក ៖ ៧៩យើងមកមុនដំបូងយើងនៅនារីសិន យើងនៅនារីដូចថាយើងខាងទូលអង្ករ ឬក៏ទូលគ្រាប់សិន ។

ឈុនលី ៖ ខាងស្បៀង?

ធួក ៖ ហ្នឹងខាងដឹកជញ្ជូន យើងទូលយកទៅភ្នំយកទៅទូលទៅខ្លាំងរាប់ចឹងទៅ ដើរតាមព្រំដែនតាមនេះ យើងទូលយក.....។ ដល់ក្រោយមកបានដូចថាយូរៗចេះតែ ចុះវាសុទ្ធតែប្រុសហើយនឹងស្រីនឹង ដល់ចឹងតែវាមានអ្នកដឹកនាំ គេមានក្រុមៗគេ តាមកងតូចកងធំចឹងទៅគេចេះតែសួរទៅយូរៗទៅគេបានប្តីបានប្រពន្ធអស់ទៅ អ៊ំទៅការនៅបឹងបេងនោះ ។

ឈុនលី ៖ ឃុំបឹងបេង?

ធួក ៖ អឺ! ទៅរៀបនៅបឹងបេង បើការណារៀបនៅនេះគេមិនឲ្យរៀបទេ ។

ឈុនលី ៖ ម៉េចចឹង?

ធួក ៖ ពីព្រោះអីកាលណាយើងចេះបាក់រៀបទៅ វាអត់មានអ្នកណាដឹកជញ្ជូន ម្លេះហើយទាល់តែអ្នកណាដូចថាយើងស្រឡាញ់ចឹងទៅ មករៀបនៅកន្លែង....ចាស់ បើក្មេងគេមិនឲ្យរៀបទេ កាលណាយើងរៀបទៅវាបាក់ៗ វាចេះរៀបៗទៅ ម្លេះហើយអ្នកខ្លះចេះអត់ចិត្តគេថាម៉េចនោះចេះរៀបបានៗ ដល់ចឹងហើយគេទៅរៀបខាងតូចៗវិញអ្នកខ្លះ ។ ដល់តូចៗគេរៀបឲ្យចុះគេយកចិត្តយើងផ្ញើទ័ព ។ ជឿ?

ឈុនលី ៖ ចា៎! ហើយចឹងពេលដែលរៀបនឹង កាលនឹងអ៊ំអាយុប៉ុន្មាន?

ធួក ៖ កាលនឹងឆ្នាំ៨២ អាយុ២៣ ។

ឈុនលី ៖ ២៣ឆ្នាំ?

ធួក ៖ អឺ! ឥឡូវអាយុ៩១ហើយ ។

ឈុនលី ៖ ហើយខាងគ្រួសារនឹង គាត់ខាងទ័ព?

ធួក ៖ ទ័ព ។

ឈុនលី ៖ ជួបគ្នានៅនឹងស្រឡាញ់គ្នាទៅ?

ធួក ៖ អឺ!

ឈុនលី ៖ ហើយរៀបនឹងប៉ុន្មានគូ តែឯង?

ធួក ៖ រៀប ។

ឈុនលី ៖ តែម៉ាគូនឹងទេ?

ធួក ៖ មាន៣ ពីព្រោះសម័យនឹង គឺយើងមិនទាន់បាត់ ប៉ុនដល់ពេលអ្នកខ្លះគេរៀបចឹងទៅ គេអង្គុយដូចយើងជុំគ្នាចឹង និយាយអ្នកធំគេនិយាយ ជូនកាលគេមានមីមានអីស្រុះទៅគេប្រកាសគេនិយាយអីចឹងទៅ ។ ដល់ពេលអ៊ំរៀប៣គូនឹង គឺបានផ្ទឹមបន្តិចដែរ ផ្ទឹមម្នាក់ម្តងៗ វាដូចចាប់ដៃតិច ផុតចាប់ដៃតិច ។

ឈុនលី ៖ កាលនឹងអ្នកណាគេ អ្នករៀបឲ្យ មានមេក្រុមមេអង្គភាពគេអត់?

ធួក ៖ អង្គភាពគេរៀបឲ្យ អ្នកទទួលខុសត្រូវទាំងអស់គេរៀបឲ្យ ដូចថាគេទទួលខុសត្រូវម៉ាបឹងបេងនឹង ដល់នេះគេរៀបឲ្យ ។

ឈុនលី ៖ ចឹងមូលហេតុអីគេខ្លាចថាឲ្យតែការហើយអត់ទៅធ្វើការទៀតអីចឹង?

ធួក ៖ តែការហើយយើងនៅប្រជាជន មានបានទៅដឹកជញ្ជូនណា ពីព្រោះយើងនៅជាគ្រួសារមានគ្រួសារហើយយើងនៅម៉ាវគ្គទៀតហើយ យើងចេញពីកន្លែងដឹកជញ្ជូនហើយ ។

ឈុនលី ៖ ចឹងបានន័យថា ឲ្យតែការហើយគឺចេញពី?

ធួក ៖ ហ្នឹងហើយ ឲ្យតែការហើយចេញពីកន្លែងដឹកជញ្ជូន ហើយទៅនៅមានភូមិគេដូចថាប្រជាជនគេចឹង ប្តីទៅទាហានទៅ ប្រពន្ធនៅភូមិមួយដូចយើងចឹងទៅ ។

ឈុនលី ៖ ហើយយើងនៅផ្ទះធ្វើអី?

ធួក ៖ នៅផ្ទះ យើងដាំដំណាំតិចតួចសម្រាប់ហូបទៅដូច បេក ដូច... ។

ឈុនលី ៖ កាលនឹងមានដីនៅ ក្រែងថាដីនឹងមានមីន?

ធួក : ហ៉! មានមីនតែកាលមកមុនដំបូងគឺអត់មានទេ មានដោយកន្លែងៗ តាមព្រំដែននឹងមាន ដែរ មានកន្លែង ៗ មកមុនដំបូងនោតាមនេះម៉ុំផ្លូវចេញទៅថៃនឹង ៗ

ឈុនលី : មានមីន អ៊ំដឹងថាចុះពេលដំបូងកាលមកដែលអ៊ំចូលមកកាលពី៧៩នឹង កាលនឹងមាននៅ?

ធួក : ៧៩!

ឈុនលី : ចា៎! ដែលពេលដែលចេញពី?

ធួក : ពីនោះៗមកៗនឹងមាន តែមានដោយកន្លែងមានចឹងទៅជួនកាលទ័ពគេនៅដោះៗហើយនឹង ដាក់ដូចតែគ្នា ដោះផងដាក់ផងពេញនឹង ៗ

ឈុនលី : ខាងណាអ្នកដាក់ដំបូងមក?

ធួក : ទេ!អ្នកដាក់នឹងយើងមិនសូវដឹងដែរ វាដូចថាមិនដឹងពីព្រោះអីវាមានខ្មែរសេរី យើងនិយាយ ថាពីជំនាន់លន់ នល់ ៗ គេថាជំនាន់លន់នល់ កាលនោះវាមិនទាន់មានខ្មែរក្រហម គេមិនមក នៅការពារគេមិនដាក់ដែរ ៗ ដល់ពេលយើងខ្មែរក្រហមមកម្តង ជួនកាលខ្មែរក្រហមនឹងអ្នក ដាក់ដូចថាយើងអ្នកការពារ អ្នកណាចេញទៅ... គេហៅសម័យ៣ឆ្នាំ អ្នកណាចេញទៅថៃ គេបេះដាក់ តែវាមានដុំៗទេ ៗ

ឈុនលី : ចុះឪពុកម្តាយរបស់អ៊ំ ពេលអ៊ំមកចឹង គាត់នៅណា?

ធួក : ទេ! ម៉ែ លោកពុកអីខូចយូរហើយ តែកាលដែលអ៊ំមកនឹងម្តាយនៅ តែលោកពុកអត់នៅ ទេ ៗ

ឈុនលី : អានឹងឆ្នាំ៧៩?

ធួក : ៧៩ ម៉ែនៅបឹងបេង អឺ!នៅនេះ នៅឯម៉ាជួរគោកគូប ពេលនឹងគេជម្លៀសសម័យនឹងគេ ជម្លៀសយើងហើយ គេជម្លៀសយើងនៅសហករណ៍...យកមកទុកផ្សេងស្ងាត់ៗភូមិ ៗ

ឈុនលី : ចុះកាលអ៊ំត់ទាន់ជម្លៀសមកនឹង អ៊ំនៅនោះធ្វើអីគេ កាលអត់ទាន់មកដល់នេះ នៅជាមួយ ឪពុកម្តាយ?

ធួក : អត់ទេ នៅតាមកងដែរ ៗ

ឈុនលី : ហ្នឹងគេហៅកងអីគេ?

ធួក : គេហៅចល័តណាក្មួយ ៗ

ឈុនលី : ហើយការងារដកស្ទូងនឹង?

ធួក : អឺ! ដកស្ទូងធម្មតា ព្រឹកឡើងទៅៗល្ងាចឡើងមកវិញទៅ យប់ឡើងទៅលើកទំនប់លើកអី ថែមទៀតទៅ ម៉ោង៧ម៉ោង៨ម៉ោង៩បានមកវិញ យប់ក៏ធ្វើ ៗ

ឈុនលី : ហើយមានបងប្អូនអីទៅជាមួយអត់ អ៊ំមកជាមួយបងប្អូន?

ជួក ៖ មិនមានទេ ប៉ុនថានារីយើងនៅខ្វះទៅគេដូចថាយើងនៅម៉ាផ្ទះចឹង យើងមាន១០នាក់ ឬក៏ម៉ាកងតូច៣០នាក់ អានឹងមិនយើងទៅជុំគ្នា ។

ឈុនលី ៖ អានឹងបើកងនារីៗសុទ្ធម៉ងខាងស្ទូងដក?

ជួក ៖ អឺ! ស្ទូងដក ។

ឈុនលី ៖ ហើយចឹងកាលនឹងហូបចុកម៉េចទៅ?

ជួក ៖ ហូបចុក ហូបរួម តែហូប ។

ឈុនលី ៖ ហូបគ្រាន់?

ជួក ៖ ហូបលំបាកដែរ.... ។

ឈុនលី ៖ ហូបបបរ ហូបបាយ?

ជួក ៖ ហូបបាយ ។

ឈុនលី ៖ ចុះដូចក្នុងកំឡុងឆ្នាំ ពេលអ៊ំធ្វើការដកស្ទូងនឹង ដូចថាមានដែលជួយអ្នកណាម្នាក់អីអត់ ដូចថាឃើញគេអត់បាយ ឬក៏ឈឺ ជួយលាក់ ជួយអី?

ជួក ៖ ទេ! រឿងថាជួយចេះតែជួយហើយយើងដូចថា ពេលធ្វើការចឹង បើសិនណាជាយើងមានក្រុមយើង១០នាក់ បើសិនណាយើងមានក្រុម១០នាក់ចឹង បើសិនណាជាអ្នកណាដែលធ្វើការរៀងច្រើនចឹង អត់ទោះបីអត់ឈឺអីក៏យើងឲ្យគេឈប់ទៅ យើងនិយាយទៅកុំឲ្យគេដឹងកុំឲ្យគេថាកងតូចគេដឹង យើងនៅត្រឹមៗក្រុមយើង ថាឥឡូវឯងនោះគេទៅធ្វើយូរហើយម៉ាអាទិត្យឬក៏១០ថ្ងៃចឹង យើងឲ្យអ្នកនោះសម្រាកទៅអត់អីទេ ហ្នឹងហើយអ្នកណា ។

ឈុនលី ៖ ចុះបើគេសួរយើងប្រាប់ថាម៉េច?

ជួក ៖ គេសួរយើងប្រាប់ថាឈឺដើង ឬក៏អីចឹងឈឺ ។

ឈុនលី ៖ តាមពិតអត់ឈឺទេ?

ជួក ៖ អត់ឈឺទេ តែនេះពេក តែវាហត់ពេក ។

ឈុនលី ៖ ចុះអ៊ំដែលសម្រាកខ្លួនឯង?

ជួក ៖ សម្រាក ។

ឈុនលី ៖ គេជួយករយើងវិញ គេជួយលាក់យើងវិញដែរ?

ជួក ៖ គេជួយមិនអីទេ វាដូចថាយើងទៅនៅស្គាល់ចិត្តគ្នាវាស្រួលដែរនឹងហើយ តែវាស្រួលដោយកន្លែងៗ កន្លែងណាពិបាកៗណាស់ យើងមិនទៅធ្វើការចឹង ជួនកាលគេអត់ឲ្យបាយហូបដែរ គេតឹងតែង គេមិនឲ្យបាយហូបដែរ ជួនកាលគេអូសគេទាញដែរនឹងទៅស្រែទៅអីនឹងតែវាដោយកងដោយក្រុមអីណា ។ អ្នកណាគេល្អៗទៅ អ្នកណាគេអាក្រក់ៗទៅ ។

ឈុនលី ៖ ហើយចឹង គិតទៅពី៧៥ដល់៧៩អ៊ំអត់មានជម្លៀសទៅណា នៅធ្វើការនៅនឹង?

ធួក ៖ ជម្លៀស ។

ឈុនលី ៖ ទៅខាងណាវិញ?

ធួក ៖ ដូចថាអ៊ំនៅម្ដុំនិមិត្តនឹង ដល់ពេល៧៥គេឲ្យយើងចេញៗអ៊ំទៅខាងម៉ាដួរៗអូរតាភូ ក្រោយគោកតូចនឹង គេហៅអូរតាភូអីនោះ ។

ឈុនលី ៖ អានឹងស្រុកអីគេ?

ធួក ៖ អូរតាភូនឹងវានៅក្រោយគោកតូច នៅដងអារញ្ញនឹងណា ។ អត់ដែលស្គាល់អូរតាភូ?

ឈុនលី ៖ ខេត្តអីគេ អត់ស្គាលផង ។

ធួក ៖ ដែលស្គាល់គោកតូចៗយើងនេះ?

ឈុនលី ៖ គោកតូចអត់ស្គាល់ដែរ ។

ធួក ៖ អឺ!

ឈុនលី ៖ អានឹងនៅក្នុងស្រុក នៅក្នុងខេត្តអីគេ?

ធួក ៖ ខេត្តបន្ទាយមានជ័យយើងនឹង វានៅម៉ាដួរគោកធំយើងនឹង គេហៅម៉ាដួរនេងអៀង ម៉ាដួរ អឺ!ថៅកែយ៉រ វាទៅក្រោយចេះនៅក្រោយគោកតូច ភូមិគោកតូចយើងទៅពីកូនដំរីវានៅតាមយ៉រចេះមាត់ព្រៃ វានៅក្រោយនឹងទៀត ។ ដល់អ៊ំទៅពីនិមិត្តទៅ វាទៅខាងនោះ ទៅឯងលិចគេហៅអូរតាភូ ម៉ាដួរស្អីម៉ាដួរគេហៅអូរតាភូ ម៉ាដួរវាំងមួង ។ ស្គាល់វាំងមួងទេ?

ឈុនលី ៖ អត់ដែលស្គាល់?

ធួក ៖ វាំងមួងនឹងនៅកន្លែងគោកធំយើងនឹង ។

ឈុនលី ៖ មានគោកតូច គោកធំ?

ធួក ៖ អឺ! ហើយវាំងមួងនឹងនៅក្រោយគោកធំនឹងទៀត អាគោកធំយើងនេះវាំងមួង ដល់ត្រឡប់ចេញពីកូនដំរីនឹងមកនៅម៉ាដួរវាំងមួងបានយើងរត់មកគោកធំវិញ ។ ដល់ពេលលើកក្រោយគេឲ្យទៅមែនទែន គេជម្លៀសមែនទែនៗទៅខាង.....ស្តោ ។ ស្គាល់ទេ...ស្តោ?

ឈុនលី ៖ អត់ស្គាល់?

ធួក ៖ ថ្មគោល ។

ឈុនលី ៖ ថ្មគោលស្គាល់?

ធួក ៖ អឺ!

ឈុនលី ៖ តែអានឹងឈ្មោះពីដើមគេហៅចឹង?

ធួក ៖ ឈ្មោះពីដើម ថ្មគោល ....ស្តោនឹង ។

ឈុនលី ៖ ជ្រោយស្តៅនឹង បើគិតទៅជាអី ជាភូមិជាឃុំជាស្រុក?

ធួក ៖ ឥឡូវអត់ដែលពុទេ?

ឈុនលី ៖ ខ្ញុំដែលពុតែថ្មគោល ។

ធួក ៖ ថ្មគោល ជ្រោយស្តៅនឹង វាជិតគ្នានឹង វាចឹងគ្នាថ្មគោលជ្រោយស្តៅនឹង ។

ឈុនលី ៖ ស្រុកថ្មគោល?

ធួក ៖ អឺ! ថ្មគោល ដល់ពេលទៅដល់ថ្មគោលហើយបានគេហៅនារីៗត្រឡប់មកវិញចូលជុំគ្នារៀបជាចល័តវិញហើយ ។ អានឹងយើងនិយាយ៧៥ ៧៦ម៉ងនឹងណា ។ ដល់មកដល់៧៩បានទ័ពយើងខាងនេះ បានគេចូលមកដល់ តែចូលនឹងយើងនៅខ្មែរក្រហម ក៏នៅតែដូចថាយើងវារត់ទៅវាអត់មានខោអាវ ដូចថាខោអាវយើងៗទៅធ្វើការចឹង យើងទុកខោអាវ ដល់តែពេលយើងទៅធ្វើការចឹងសម្រាប់តែទ័ពនឹងគេចូលមក គេបាញ់តុងតាំងៗ អត់បានខោអាវចោលខោអាវ ។ ដល់ចឹងចេះតែសុំគេស្លៀក អ្នកណាគេមានសុំគេម៉ាកំប្លេះ២មក ចេះស្លៀកទៅ ។

ឈុនលី ៖ ចឹងគេអត់មានចែកខោអាវឲ្យ?

ធួក ៖ គេចែកឲ្យដែរ តែពេលនឹងយើងរត់ចោលនោះ បើគ្រាប់មក ។

ឈុនលី ៖ គ្រាប់បាញ់មក?

ធួក ៖ អឺ! គ្រាប់បាញ់សុវាន់ធីណៃអឺបាញ់មកម៉ង បាញ់ពីថ្នល់កូនដំរីនឹងជះមកឯងវាលស្រែងត្បូង ដល់ចឹងយើងរត់ ។

ឈុនលី ៖ ហើយចឹងពេកអ៊ំរត់មកនឹងមានគ្នាច្រើនទេ?

ធួក ៖ មានច្រើន ខ្លះអឺរាប់រយ ។

ឈុនលី ៖ ខាងណាខ្លះទៅ?

ធួក ៖ ម៉ាចល័តខ្ញុំនៅនឹង ។

ឈុនលី ៖ ហើយមានអ្នកមកពីក្នុងថែមទៀតអត់?

ធួក ៖ មិនមានទេ ដឹងថាចល័តនៅ ។

ឈុនលី ៖ ចុះអ៊ំថាមកដល់ភ្នាមមានព្រៃមានអីចឹង?

ធួក ៖ មានព្រៃមើលមិនឃើញទេ ។

ឈុនលី ៖ បើមើលទៅសភាពការណ៍នឹង វាម៉េចទៅពេលនឹង ស្ថានភាពនៅនឹងមើលទៅវាម៉េចទៅ?

ធួក ៖ សភាពការណ៍នឹង វាលំបាក វាយ៉ាប់នឹងឯង តែយើងចេះតែ ។

ឈុនលី ៖ បើគិតទៅលំបាកៗអីជាងគេ លំបាកអីខ្លះ?

ធួក ៖ អឺ! លំបាក តែសម័យនឹងយើងវានៅជុំគ្នា វាដូចថាវាគ្មានលុយចាយរបស់ហូប ក៏គេបើកឲ្យយើង ក្នុងម៉ាខែចឹងម្នាក់ជួនកាលបានត្រីខម៉ាកំប៉ុង ឬ២កំប៉ុងទេ ។ ដល់ចឹងយើងចេះតែនៅទៅ អាខ្វះទៅរកត្រីនៅមាត់អូរទៅៗជញ្ជាត់ទៅអីទេ ចេះហូបធម្មតា ប្រហុកអីចឹងដែលគេយក អ្នកដឹកនាំយើងគេទិញមក គេទិញទាំងឡានៗអង្ករគេបើកឲ្យយើងហូបទៅ ។

ឈុនលី ៖ មានអ្នកដឹកនាំនៅនឹងច្រើន?

ធួក ៖ មាន ។

ឈុនលី ៖ ប៉ុន្មាននាក់?

ធួក ៖ ច្រើន ។

ឈុនលី ៖ អានឹងគេហៅគេដឹកនាំតំបន់ ហើយក៏?

ធួក ៖ គេ.......... ។

ឈុនលី ៖ ទើបមកដំបូងចឹង គេហៅថាតំបន់នៅស្រុកម៉ាឡៃនេះ?

ធួក ៖ គេហៅភូមិៗដូង ។

ឈុនលី ៖ ចឹងបើគិតទៅនៅកន្លែងណាក៏ភូមិដូងដែរ ម៉្តុំនឹង?

ធួក ៖ មុនដំបូងភូមិដូងទាំងអស់ ដល់យូរៗទៅបានគេចែកជាស្រុក ។

ឈុនលី ៖ ស្រុកនឹងគេចែកពេលណា?

ធួក ៖ មើលចែកជាភូមិៗទេ ប៉ុនស្រុក មើលភូមិដូង អឺ!មុនដំបូងភូមិដូង ដល់តែយូរៗទៅគេចែកភូមិឲ្យច្រើនវិញ ដូចអាំគេហៅភូមិថ្មី ។

ឈុនលី ៖ ភូមិដូងខ្ញុំបានទៅសម្ភាសន៍ហើយ ជួបជាមួយមេភូមិទៀត ។

ធួក ៖ អើហ្នឹងហើយ គេអ្នកបានធ្វើការកង់តូចកង់អីទៅ អានឹងគេដឹងខុសត្រូវ ដល់ដូចអាំចេះវានៅតែដូចថាយើងប្រពន្ធទាហាន តែយើងនៅតែអឺ!បើយើងនិយាយទៅដូចថាយើងនៅកូនក្រុមគេ ។ ដល់ចឹងទៅយើងមិនបានគិតថាទៅប្រជុំទៅរៀនយើងអត់សូវដឹងទេ បានគេមេក្រុមមេអីគេចេះទៅរៀនទៅអី ។

ឈុនលី ៖ ចុះអាំថាទៅនៅដីថៃ អានឹងនៅជំរំនៅម៉េច?

ធួក ៖ នៅដីថៃនៅជំរំ ។

ឈុនលី ៖ ជំរំអីគេអានឹង?

ធួក ៖ គេហៅជំរំអឺ!៨៥ ។

ឈុនលី ៖ ជំរំ៨៥?

ធួក ៖ អឺ!៨៥ ឆ្នាំ៨៥យើងចូលដីថៃ បានគេហៅជំរំ៨៥ ។

ឈុនលី ៖ ចឹងបើគិតទៅមូលហេតុអីបានឆ្លងទៅដីថៃឆ្នាំ៨៥ហ្នឹងម៉ង?

ធួក ៖ ចុះបើទាហានថៃ ........មក ទាហានខាងនេះ ។

ឈុនលី ៖ មកកាន់តែគៀកហើយចឹងបានយើងរត់ចូល?

ធួក ៖ គេបោសសំអាតបណ្ដោយ គេបោសសំអាតតាមព្រំដែននេះរហូត អត់មានអ្នកណានៅបានទេ តែទ័ពអាចមកវិញ ទ័ពអាចទៅដល់ដីថៃនោះដែរ តែមានយប់ឡើងចឹងគេចូលមកវិញ ។

ឈុនលី ៖ ចា៎! ចេញចូលៗ?

ធួក ៖ អឺ! ដល់ទាហានខាងនេះ វ៉ៃដែរ តែវ៉ៃម៉ាភ្លែតអត់នៅទេ វ៉ៃហើយដាក់នេះគេថយទៅនៅដូចថាស្រះខ្មែរសេរីអីចឹងចុះ ។ ដល់ចឹងទាហានខ្មែរក្រហមគេជិះឡានជិះអីតាមថៃ និយាយចឹងគេមកដូចថាបើនិយាយទៅ គេមកវ៉ៃឈ្លបកុំឲ្យយើងដេកបាននៅបាន ។ បើកាលណាយើងមិនធ្វើចឹង បើយើងមិនវ៉ៃមិនអីយើងគេម៉េចចិញ្ចឹមយើង ចាំមើល គេឲ្យយើងមកធ្វើខ្លះណាគេឲ្យជំនួយឲ្យបាយ ឲ្យអង្ករហូបមិនធ្វើអីមិននេះ ។ ដល់ហើយចេះវ៉ៃទៅចឹងទៅ ដល់ពេល៩៣ ពួកអ៊ុនតាក់ចូលមកនឹងបានគេយក ។ យកមកមីងអីស្មានតែគេនឹង យកទៅក្នុងដែរ ដល់ពេលគេយកមកដាក់នេះ មិនដឹងថាឯងខ្មែរក្រហមទៀត អត់ដឹង ។

ឈុនលី ៖ អត់ដឹង?

ធួក ៖ អត់ដឹង ស្មានចង់ទៅនឹងគេ ចង់ទៅដល់ស្រុក ។

ឈុនលី ៖ ចង់ចូលទៅក្នុងដែរ?

ធួក ៖ ចង់ចូលដែរ ។

ឈុនលី ៖ ហេតុអីបានយើងទៅអត់រួចចឹង?

ធួក ៖ ពីព្រោះយើងៗទៅមិនរួចក្នុងនឹង គឺអ្នកដឹកនាំយើងនៅមានខ្មែរក្រហម បើដូចជំរំនោះគេអត់មានខ្មែរក្រហមទេ គេឲ្យទៅទាំងអស់ ។ ដល់យើងនៅ៨៥នឹង យើងប្រពន្ធទាហាន យើងដូចថាអ្នកដឹកនាំយើងនឹងគេនៅខ្មែរក្រហម គេនៅរបបនឹងគេមានទាន់ចោលណា ។ ដល់ចឹងយើងនៅនេះទៅ ដល់ក្រោយមកបានផ្ដាច់ខ្លួន ។

ឈុនលី ៖ ផ្ដាច់ខ្លួនឆ្នាំណា?

ធួក ៖ ឆ្នាំ៩៣ៗគេយាយអ៊ិត ។

ឈុនលី ៖ បោះឆ្នោត?

ធួក ៖ អឺ!៩៣ពួកអ៊ុនតាក់ចូលមក តាមមើលបែប៩៤នេះឯងត្រូវគ្នា ចុះយើងត្រូវគ្នាខ្មែរក្រហម

ឈុនលី ៖ ៩៤ ឬ៩៦ ព្រោះពេលសម្ដេច ក្រែងថាសម្ដេចហ៊ុន សែន មកនឹងៗដូចជាឆ្នាំ៩៦ ៩៧ ដឹង ហើយចឹងពេលនឹងផ្ដាច់ខ្លួន?

ធូក ៖ អឺ! អានឹងបានខ្មែរក្រហមគាមនឹងផ្ដាច់ខ្លួនមែនទែនហើយ ។

ឈុនលី ៖ ចុះអឹមកពីថៃ ពេលដែលយើងចេញពីថៃ មកនៅលើទឹកដីយើងនេះ អានឹងនៅពិតប្រាកដម៉ង អានឹងឆ្នាំណា ដូចថាយើងលែងចេញចូល?

ធូក ៖ ដែលយើងចេញចូលបាន ។

ឈុនលី ៖ ដូចយើងថាយើងឈប់ចេញចូលទៅនឹងទៀតហើយ យើងមកនៅនេះមែនទែន?

ធូក ៖ ដែលពិតប្រាកដមានតែឆ្នាំ៩៣នឹងឯង យើងមកអត់មានទៅណាទៀតទេ មកនឹងយើងនៅនឹងរបូត ទោះបីថាយើងវៃតប់គ្នាទៅតែប្ដីៗទេ តែយើងនៅនឹងរបូត ដូចថាយើងខ្វាចដែរ ពេលណាដូចថា វៃមកសំរុកមកហើយ សំរុកមកចឹង ។ យើងគ្រាន់រៀបចំខោអាវទៅនៅមាត់អូរ ។ តែអត់ដូចថាវៃដែរ តែអត់វៃទ្រង់ទ្រាយធំ ។

ឈុនលី ៖ ចុះដូចថាខ្ទង់ឆ្នាំ៩០ ៩១ ៩២ អ៊ឹដែលចេញចូលនឹង?

ធូក ៖ ៩១ ៩២ មិនទាន់មកដល់ពីដីថៃផង ។

ឈុនលី ៖ នៅដីថៃហ្នឹងម៉ង?

ធូក ៖ ហ្នឹងហើយ បើ៩៣បានមកហើយ ទាល់តែអ៊ុនគាត់ចូលមកបានយកមក បាននាំមក ។

ឈុនលី ៖ ហើយចឹងចូលមកដំបូងចឹងមានមីនមានអីដែរ ហើយព្រៃអីដែរ?

ធូក ៖ មានព្រៃ ។

ឈុនលី ៖ ហើយធ្វើម៉េចនៅបាន?

ធូក ៖ ចេះដោះទៅ រាយៗទៅ ។

ឈុនលី ៖ អ្នកណាអ្នកដោះទៅ?

ធូក ៖ ទេ! ជាគ្រួសារៗរបស់គេ ដូចប្ដីប្រពន្ធគេចឹង ដូចថាគេចង់ទៅនៅត្រង់ណាគេរាវត្រង់នឹងទៅប្ដីគេនឹង ហើយបាននាំប្រពន្ធទៅនៅ ដូចថាដីមីងចឹង ប្ដីគេមករាវទៅដូចថាយើងស្រឡាញ់ដីប៉ុនណា យើងចាប់ប៉ុនណា យើងនាំគ្នារាវទៅ អត់មាននេះយើងចេះនៅទៅ ។

ឈុនលី ៖ ហើយអឹចេះរាវនឹងគេដែរ យើងស្រីៗរាវដែរ?

ធូក ៖ ទេ! រាវនោះ បើនិយាយថាមីននោះ បើគេថាអាស្លាប់នោះរាវពិបាកណាស់ ។

ឈុនលី ៖ មីនស្លាប់នឹង?

ធូក ៖ អឺ! អាស្លាប់នឹងនៅច្រើនពីមាត់អូរមកវិញ ។

ឈុនលី ៖ អានឹងភាគច្រើនខាងណាដាក់ស្លាប់នឹង?

ធូក ៖ ខាងនោះ ។

ឈុនលី ៖ ខាងក្នុង?

ធួក ៖ អឺ!

ឈុនលី ៖ ចុះវៀតណាម?

ធួក ៖ អឺ! ហ្នឹងឯង តែអានឹងមានត្រឹមមាត់អូរឡើង ពីមាត់អូរឡើងមកប្រហែលខ្ទង់៤០ម៉ែត្រ ៥០ម៉ែត្រ ឬ១០០ម៉ែត្រអានឹងអាស្មាច់ ដល់ផុតពីនឹងមកមានរបងគេៗចឹងហើយ បាន មានអាពោតគេហៅស្នូលពោត ដែលឃើញទេ ដែលពួកគេនិយាយ?

ឈុនលី ៖ ដែរៗខ្ញុំដែលឃើញដែរតើ ។

ធួក ៖ អឺ! ម៉ាវគ្គនឹងគឺមានស្នូលពោតគេមានរបងគេ គេឈប់ដាក់អាស្មាច់ៗគេដាក់មកពីមាត់អូរ ប្រហែល៥០ម៉ែត្រ ឬ១០០ម៉ែត្រគេឈប់ហើយ មានរបងគេមួយ ។ ផុតពីនឹងគេដាក់ អាពោតគេរាយ គេដាក់អាស្នូលពោតស្នូលអីនឹងគេហៅអាគូថទន់អីនឹង អំនៅនេះនាមតែ នៅ ប៉ុនមីនក៏មិនទាន់ស្គាល់អស់ដែរ ជួនកាលអត់ដឹងដែរ ។

ឈុនលី ៖ ខ្ញុំធ្លាប់ឃើញមីនគោន ធ្លាប់ឃើញមីនស្នូលពោត ខ្ញុំធ្លាប់ឃើញ ។ ហើយបើគិតទៅភូមិដែល អំនៅដំបូង ចាប់ពីផ្ទះដោះមីនបានទំហំប៉ុនណា ដោះមីនបាន ចង់និយាយថាបានដីប៉ុនណា នៅមុនដំបូង?

ធួក ៖ មុនដំបូងនៅមាត់ឯអូរ ។

ឈុនលី ៖ ហើយចុះមកនៅនេះឆ្នាំណា?

ធួក ៖ ដល់ពេលយើងនៅមាត់អូរចឹង ដល់ពេលប្រហែលជាយើងនៅខ្ទង់ប្រហែលកន្លះឆ្នាំ ឬក៏ខ្ទង់ ៣-៤ខែចឹង យើងដូចខាងនោះវាចង្អៀតពេក យើងឃើញខាងនោះថ្មល់ជាតិ យើងចេញ មកខាងនេះមកចាប់ទៀតមក ។

ឈុនលី ៖ ហើយប៉ុន្តែនៅនេះមានមីនដែរ?

ធួក ៖ នៅនេះដូចជាគ្មានទេដឹង បើនៅនោះមានម៉ាជួរមាត់អូរមានៗ បើនេះដូចជាមិនមានៗខ្លះ អត់ខ្លះ ដូចថាដែលនៅព្រៃចឹង អ្នកណាគេបោសដី គេស្រឡាញ់ប៉ុនណា ត្រឹមណាចឹង គេ មើលដីគេ បើមានគេដោះចេញ ។

ឈុនលី ៖ អានឹងធ្វើម៉េចមើលដឹង?

ធួក ៖ ទេ! អាក្តារអាអីនឹងគេដឹងតើ គេមើលតាមខ្សែវា គេដាក់មានខ្សែគេ ។

ឈុនលី ៖ ចឹងខ្សែនឹងនៅលើគោក?

ធួក ៖ អឺ! ខ្សែនៅលើគោក ជួនកាលវាមានខ្សែ ជួនកាលវាមានដូចថាខ្សែមីនយើងនិយាយថា ខ្សែមីន គេដោះចឹងទៅ វាមានខ្សែវាគេដោះចឹងគេដឹងខ្សែវា ។

ឈុនលី ៖ តែបើយើងមើលខាងក្រៅចឹង ឃើញខ្សែវាអត់ ឬមួយខ្សែនឹងកប់ដី?

ធួក ៖ ទេ! ខ្មែរៗតែ ជួនកាលខ្មែរ បើនិយាយអាស្នូលពោតអីមានតើ ឃើញគេដាក់បន្តោលដាក់អីតើ បើយើងដើរទាក់ខ្សែបែបនេះដឹង ។

ឈុនលី ៖ ផ្ទុះ?

ធួក ៖ ហ្នឹង ។

ឈុនលី ៖ ហើយបើផ្ទុះអាចផ្ទុះទាំងអស់ ព្រោះមកទាំងខ្សែ?

ធួក ៖ ដូចមិនសូវដឹងដែរនឹង មិនសូវដឹងដែរ ប៉ុន្តែបើយើងដើរទាក់វាផ្ទុះ ។

ឈុនលី ៖ ចឹងអ៊ំបើគិតទៅកាលអ៊ំនៅជំរំអីចឹង ការហូបចុកអីគ្រប់គ្រាន់ដែរ បើយើងភៀសខ្លួនទៅចឹង?

ធួក ៖ មិនអីទេ ដូចការខ្វះខាតចេះខ្វះខាតហើយ ក៏ប៉ុន្តែយើងស្វាវាពិបាកចេះ ជួនកាលគេបើកអង្ករឲ្យយើងចឹង យើងទាហានដូចថាហូបមិនអស់ចឹង យើងយកមក ថៃគេអត់ចេះចាយលុយទេ គេចាយដែរ តែអ្នកឯងចង់យកអង្ករទៅដូរស្ពៃ ដូរជាបន្លែជាត្រីអីគេដូរឲ្យ បើយើងមានលុយ ក៏គេលក់របស់មានសព្វគេលក់ ។

ឈុនលី ៖ ប៉ុន្តែកាលនឹងយើងចាយធម្មតា?

ធួក ៖ អ្នកណាមានលុយក៏យកទៅទិញទៅ អ្នកណាមានអង្ករក៏យកទៅដូរទៅ គេអត់ប្រកាន់អីទេ ប៉ុន្តែគេគិតតាមនឹង ។

ឈុនលី ៖ ហើយចឹងដូចស្បៀងអីចឹងខាងណាអ្នកឲ្យផ្គត់ផ្គង់អ្នកនៅថៃនឹង?

ធួក ៖ ហ៉ើ! យើងមិនសូវដឹងទេ អារឿងនឹង នៅលើគេអ្នកធំគេដោះស្រាយយើងអត់សូវដឹង តែយើងនៅជាប្រជាជនចឹងទៅ គេពេលគេបើកឲ្យគេហៅយើងទៅបើកឲ្យ គេមានឃ្លាំងគេ គេបើកឲ្យយើងហូប មានកន្លែងគេឲ្យយើង ។

ឈុនលី ៖ ចុះដល់ពេលៗត្រឡប់មកវិញដូចជាឆ្នាំ៩៣ ពេលដែលយើងចេញពីថៃ គេនៅផ្គត់ផ្គង់យើងទៀតអត់ ដូចស្បៀងអីចឹង?

ធួក ៖ នៅផ្គត់ ។

ឈុនលី ៖ បានគ្រប់គ្រាន់ទេ ពេលនឹង?

ធួក ៖ ដឹងតែដូចថាម៉ាខែគេឲ្យយើងម៉ាគោ ។

ឈុនលី ៖ ម៉ាគោអង្ករ?

ធួក ៖ ម៉ាបៅតប្រេងកាតយើងនឹង គេឲ្យយើងម៉ាគោម្នាក់ ។

ឈុនលី ៖ ម៉ាខែ?

ធួក ៖ ម៉ាខែ ។

ឈុនលី ៖ ចុះបើគ្រួសារ?

ធួក ៖ ហើយកូនតូចប៉ុននេះក៏គេឲ្យ ។

ឈុនលី ៖ ម៉ាគៅដែរ?

ធួក ៖ អឺ!ម៉ាគៅដែរ តែដល់ក្រោយមកបានគេឲ្យដូចថា វាប្រហែលជា២ឆ្នាំ៣ឆ្នាំ បានគេបន្ថយទៅជាតិចវិញ ដូចថាកូនតូចចឹងគេឲ្យជា ។

ឈុនលី ៖ ប្រហែលជាស្បៀងខ្វះ ឬម៉េចបានចឹង?

ធួក ៖ យើងគេឲ្យព្រឹកម៉ាកំប៉ុង ល្ងាចម៉ាកំប៉ុង ហើយដល់យើងគេឲ្យហូបគ្នា៣នាក់ ឬក៏២នាក់ចឹង យើងហូបអត់អស់ទេ ជួនកាលព្រឹកចឹងយើងដាក់២កំប៉ុង ល្ងាចម៉ាកំប៉ុងកន្លះអីចឹងវាមិនសល់កន្លះកំប៉ុង វាសល់អត់អីទេ ។ ហូបចុកអីអត់មានដូចថា ខ្វះខាតអីដូចជាមិនសូវមានទេ តែចំពោះតែប្រពន្ធ័ពទេ ។

ឈុនលី ៖ ចុះបើ?

ធួក ៖ តែបើប្រជាជនអត់សូវដឹងទេ ពីព្រោះប្រជាជនគេបើផ្សេង ។

ឈុនលី ៖ ចឹងបានន័យថានៅនេះ មានទាំងទ័ព មានទាំងប្រជាជនទៀត?

ធួក ៖ អឺ!

ឈុនលី ៖ ចុះប្រជាជននឹងគាត់ធ្វើអីដែល អត់មានជួយខាងដឹកជញ្ជូនដែរ?

ធួក ៖ ប្រជាជនគេនាំគ្នាដឹកជញ្ជូនទៅ ដូចថាពេលត្រូវការចឹងគេយកប្តីៗទៅ៨-១០នាក់ ឬ២០នាក់អីចឹង ដូចថាយើងទៅខាងណាចឹង គេត្រូវការយើងទៅៗ តែប្រពន្ធនៅផ្ទះ តែដល់ពេលរបបប្រជាជនអត់សូវដឹងទេ មិនដឹងថាគាត់ខ្វះខាតឬយ៉ាងម៉េចយើងអត់ដឹង តែបើទ័ពដឹងថាម្នាក់ម៉ាកំប៉ុង ។

ឈុនលី ៖ ចឹងហូបអត់ដែលខ្វះ?

ធួក ៖ អត់ដែលមានខ្វះទេ រឿងហូប កម្រមានខ្វះមានអ្នកណាថាខ្វះណាស់ បើថាប្រជាជនអត់ដឹងទេ ។

ឈុនលី ៖ ចឹងក្នុងពេលនឹងសង្គ្រាមនៅតែរាំរ៉ៃចឹង ៩៣ ៩៤ចឹង?

ធួក ៖ ហ្នឹងហើយ តែប្រជាជនគេ ដូចថាគេមានដាំដូចថាដាំដំឡូងធ្វើស្រែគេបាន ហ្នឹងហើយ ។

ឈុនលី ៖ ចុះយើងអត់មានដាំអីបាន?

ធួក ៖ យើងប្រពន្ធ័ពអត់មានធ្វើអីទេ ពីព្រោះអីដូចជាមិនមានអ្នកណាធ្វើកើត ។

ឈុនលី ៖ ហេតុអីបានចឹង?

ដូក ៖ ចុះយើងប្ដីទៅមុខ យើងមិនមាំមួនណា យើងនៅចាំពេលត្រៀមចាំពេលរស់ យើងមិនមែនថានៅរៀងដូចថាយើងនៅស្រួលបួលមិនមែនទេ យើងនៅរៀបចំអីវ៉ាន់ ពេលណាដែលល្ងាចឡើងចឹង អានឹងយើងដូចពុគ្រាប់មកជិតណា ពេលប្ដីទៅមុខចឹងយើងក៏អត់មានសប្បាយចិត្តដែរ ភ័យរហូត។ ដូនកាល គេវៃនេះវៃនោះ យើងចេះខ្លាចទៅ ណាប្ដីទៅមុខណាកូនមួយពីរមិនចឹង ហ្នឹងហើយចឹង ពេលពុគេថាសភាពការណ៍ចេះចុះទៅ យើងចេះរៀបចំអីវ៉ាន់បាត់ភ័យទៅ អាប្ដីនៅនោះ ខ្លាចគេរត់លូនទៅយើងភ័យរបូត ធ្វើអីក៏អត់កើតដែរ បានតែស៊ីកក្រៃ បានល្ពៅត្រឡាចប៉ុននឹងទេ ភាគច្រើនប្រពន្ធទ័ពបានតែប៉ុននឹងទេ។

ឈុនលី ៖ បានម៉ាហូបចុក?

ដូក ៖ ហ្នឹងហើយ ឲ្យតែថា។

ឈុនលី ៖ ចុះពេលនឹងអ៊ំមានកូនប៉ុន្មានហើយ?

ដូក ៖ ទេ! កូនឆ្នាំ៨៣ ៨៤ ៨៥ហើយនឹងមានកូនមួយ។

ឈុនលី ៖ ចឹងពេលនឹងកូននឹងនៅថៃ កើតនៅថៃ?

ដូក ៖ អត់ទេ កូននឹងកើតនៅខ្លាងាប់ ពីព្រោះយើងការនៅបឹងបេង គេដាក់ទៅខាងនោះវិញ គេដាក់ទៅខាងស្រុកសំពៅ អ៊ំទៅនៅខាងខ្លាងាប់ កើតខ្លាងាប់បានម៉ាឆ្នាំហើយបានទៅចេញទៅថៃ។ ទៅនៅថៃបានមួយទៀតមក ហើយបានមកនៅនេះវិញ អេ!នៅថៃបាន២ ប្រុស១ស្រី១ ដល់មកនៅនេះបានមួយឈប់យកហើយ ពិបាកពេក។

ឈុនលី ៖ មកនៅនេះ៩០ប៉ុន្មាន ៩៣?

ដូក ៖ ៩៣។ កូនធំៗអស់ហើយ ប៉ុនចង់ប៉ុនប្អូនឯងអស់ហើយ។

ឈុនលី ៖ ៨០ជាងអាចដំណាលៗខ្ញុំ ខ្លះបងខ្ញុំ កូនបង៨០ប៉ុន្មាន?

ដូក ៖ កូនបងអាយុ២៧ ២៨ហើយ។

ឈុនលី ៖ អូ! បងខ្ញុំទៀត?

ដូក ៖ ហ្នឹងហើយ ការឆ្នាំទៅមិញ។

ឈុនលី ៖ ស្រី ហើយប្រុស?

ដូក ៖ ប្រុស។

ឈុនលី ៖ កូនអ៊ំប៉ុន្មាននាក់?

ដូក ៖ កូន៤។

ឈុនលី ៖ ស្រីប៉ុន្មាន?

ដូក ៖ ស្រី២ ប្រុស២...។

ឈុនលី ៖ ឥឡូវគាត់ទៅណា?

ធួក ៖ ទៅនេះ ទៅជួយដាក់ថ្ម នេះថ្មដឹកឲ្យគេ គេឲ្យដឹកឲ្យ ។ ដល់ចឹងទៅកូនគេជួយដឹក ម៉ាជើងបានតែ១០០ ១៣០ ។

ឈុនលី ៖ រួចថ្លៃប្រេង?

ធួក ៖ រួច អត់អីទេ យើងដឹកបាន៣-៤ជើងចឹងទៅ បានលុយ៣០០-៤០០ចឹង យើងដកថ្លៃប្រេង១០០ បានចាយ ។

ឈុនលី ៖ ចុះកូនពៅរបស់អ៊ីថ្នាក់ទីប៉ុន្មានហើយ?

ធួក ៖ កូនពៅថ្នាក់ទី ឆ្នាំនេះថ្នាក់ទី១២ដឹង ។

ឈុនលី ៖ រៀនសាលាណា?

ធួក ៖ សាលាម៉ាឡៃយើង ។

ឈុនលី ៖ ដូចកូនបងៗចឹង?

ធួក ៖ កូនបានរៀនទាំងអស់ ។

ឈុនលី ៖ កូនបង?

ធួក ៖ តែកូនបងរៀនបានតិចពេក ពីព្រោះអីកាលនឹងយើងធ្វើចំការ បើសិនណាចំការឆ្ងាយក្បាលហុងហើយដល់ពេលយើងពុកទៅតែឯងចឹង យើងចេះគិតឃើញថាទៅតែឯងចឹង ខ្វល់អីទៅ ។ ហើយយើងមិនដិះអីទៅណា យើងដើរកាត់ឆ្ងាយ ។ ដល់ចឹងកូនរៀនបានតិច រៀនបានថ្នាក់ទី៣ឲ្យឈប់ នឹកឃើញខ្លាចលោកពុកទៅព្រៃទៅអីវាខ្វល់ វាអត់មានអ្នកណានៅបានជាគ្នាចឹង ខ្លាចអត់ដឹងណាណៃបានកូនទៅវាគ្រាន់ជួយមើលជួយអីចឹង ។ ហើយអ៊ីនៅផ្ទះជាមួយកូនតូចៗ ពិបាកណាស់ធ្វើចំការទាំងវ៉ូង ជួនកាលទៅចោលកូន ។ ហើយកូនរៀងធំៗហើយបានៗរៀន អាយុឡើង៧-៨ឆ្នាំបានៗរៀន ចុះយើងម៉េចហ៊ានទុកកូនចោលណាកាលណាទុកកូនចោលកូនវាតូចៗពេកគ្នាមិនទាន់ម៉េចចេះដាំបាយ ដល់ចឹងទាល់តែយកទៅសិន ។ ដល់ចំការរៀងវាលម៉ាឆ្នាំ២ឆ្នាំ បានឲ្យកូនទៅរៀនវិញ ។ ដល់ពេលនឹងយើងឈប់ទៅហើយ យើងទៅតែពេលណាដែលយើងចុះធ្វើ យើងមានពេលឈប់ខ្លះ ។ ដល់ចឹងយើងឲ្យកូនរៀនទៅ យើងនៅផ្ទះបាន ។ កាលមុនអត់ទេ កាលមុនយើងឆ្ងៀតអត់បានទេ កាលធ្វើចំការមុនដំបូង យើងក្រដង អត់មានលុយមានកាក ។ ដល់ចឹងចេះតែនាំកូនទៅហើយដឹកដៃកូនទៅទម្រាំបានមួយៗ ។

ឈុនលី ៖ ចុះដល់ពេលរៀនអីចឹង ដូចខ្ទង់៩៣ ៩៤ ទៅច្បាំងកូននឹងចូលរៀននៅ?

ធួក ៖ ដូចមិនទាន់ទេ ពីព្រោះ៩៣មកមិនទាន់មានចំការធ្វើអីនៅទេ………… ៩៣យើងទើបត្រូវគ្នា

ឈុនលី ៖ អ៊ុនគាត់តើកាលមុន?

ធួក ៖ អឺ! ហើយ៩៤ ៩៥ បានៗធ្វើចំការ ។

ឈុនលី ៖ ៩៦បានផ្តាច់ខ្លួន?

ធួក ៖ ប៉ុននឹងដឹង ។

ឈុនលី ៖ ៩៦?

ធួក ៖ អឺ!

ឈុនលី ៖ ចឹងបានន័យថាក្រោយផ្តាច់ខ្លួនបានៗកូនទៅរៀន?

ធួក ៖ នឹងឯង ហ៎! មុនកូនរៀនបានមុន ពីព្រោះអីពេលដែលកូនរៀននឹង កាលនឹងគេថាសភាពការណ៍មិនស្រួល ឲ្យអាបងហៅប្អូននឹងហើយពេលនឹងសភាពការណ៍ស្រួលនោះ បានរៀនមុន ។

ឈុនលី ៖ ទៅហៅពីសាលាមក?

ធួក ៖ ទៅហៅពីសាលា ចុះគេផ្អើលរៀបចំអីវ៉ាន់ ដល់ចឹងយើងអាកូនវាអត់ភ័យ វាអត់ដឹងវាមិនដឹងថារត់ម៉េចលូនម៉េចទេកូននឹង ដល់ចឹងវាចេះនៅនឹងទៅ ។ អាម៉ែវាថារៀបចំអីវ៉ាន់នោះខាងយួនមកដល់ត្រឹមណាៗហើយ ឲ្យបងមកហៅ............................................

បានតែកូនស្រីបានថ្នាក់ទី៩ ថ្នាក់ទី១០អី ។ ដូនកាលអាំទៅចំការចឹងទៅ មីស្រីអត់មានអ្នកណាមើលប្អូន អត់មានអ្នកណាដាំបាយឲ្យឈប់ទៀតហើយ បានថ្នាក់ទី៩ហើយនឹងឈប់ទៀត ។

ឈុនលី ៖ ទី៩គ្រាន់?

ធួក ៖ ហ្នឹងហើយឲ្យឈប់ គ្រាន់បានដាំបាយដាំទឹកអាំ ខែកាច់ពោតទៅអស់ហើយ ។

ឈុនលី ៖ នៅនេះ ការលើកមុនគេប្រើទឹកអីគេ?

ធួក ៖ អាំប្រើទឹកស្រះ ។

ឈុនលី ៖ ដូចពេលចេញមកៗនៅនេះនៅប្រើទឹកស្រះដដែល?

ធួក ៖ ប្រើទឹកអណ្តូង មុនដំបូងបើអ្នកណានៅព្រំដែនគេប្រើទឹកអូរព្រំដែន ។

ឈុនលី ៖ ទឹកអូរ?

ធួក ៖ ហ្នឹងហើយ បើអ្នកណាដែលគេមកនៅឆ្ងាយពីអូរព្រំដែននឹង គេជីកអណ្តូងគេតាមផ្ទះគេ ដល់អាំជីកស្រះ ។

ឈុនលី ៖ ប្រើទឹកស្រះ?

ធួក ៖ ស្រះប៉ុន្នឹងនេះ ។

ឈុនលី ៖ រហូតដល់ឥឡូវ?

ធួក ៖ ហ្នឹងហើយស្រះមានព្រលិតមានអី លើកមុនមានត្រី មានត្រីអីត្រីស្រែចេះចិញ្ចឹម ។

ឈុនលី ៖ ចឹងដល់ពេលក្រោយយើងផ្តាច់ខ្លួនទៅ ពូគាត់ធ្វើទំពទៀតអត់?

ធួក ៖ ធ្វើពីព្រោះអីយើង ។

ឈុនលី ៖ ត្រូវរូវគ្នា?

ធួក ៖ ធ្វើនៅតែធ្វើចឹង ពីព្រោះអីមិនចង់ធ្វើដែល ប៉ុន្តែយើងនឹកឃើញថាពេលនឹងអត់មានវ៉ែតប់អី ទេ អានឹងយើងនិយាយតែត្រូវគ្នាហើយ យើងអត់មានវ៉ែតប់ទេ ។ ហើយម្យ៉ាងក៏យើងគេ អត់ក៏គេអត់មានយកទៅណាឆ្ងាយ ដល់ចឹងចេះធ្វើទៅដើម្បីបានប្រាក់ខ្លែះ ។

ឈុនលី ៖ ចឹងបានន័យថារបបគេនៅតែបើបន្ត?

ធួក ៖ បន្ត ដល់ក្រោយមកគេទើបនឹងឈប់ប្រហែលជាម៉ាឆ្នាំទេ ។

ឈុនលី ៖ ហេតុអីបានឈប់?

ធួក ៖ ទេ! ដូចថាឈប់នឹងចង់ចេះ យើងវាធ្វើទាហាន ធ្វើទំពអីយូរ អានឹងចិត្តអ៊ំ ។ ដល់ពេលចឹង យើងចង់ឈប់ ដើម្បីថាយើងចង់រកឯកជន ដូចថាយើងចង់ធ្វើស្រែចំការខ្លួនយើង ។ យើង វាចាស់ហើយ ហ្នឹងហើយទុកឲ្យក្មេងៗវាធ្វើទៅ យើងចាស់ទៅយើងចង់ផ្អាក ។

ឈុនលី ៖ ទើបឈប់ឆ្នាំនឹង?

ធួក ៖ ឈប់ឆ្នាំនឹង ។

ឈុនលី ៖ ចុះអ៊ំចង់ដឹងថា ដូចអ៊ំឆ្លងកាត់មកប្រវត្តិលំបាកអីចឹង ដែលចាញ់?

ធួក ៖ ចាញ់ មកមុនដំបូងចាញ់ ។

ឈុនលី ៖ អ៊ំដែលចាញ់?

ធួក ៖ មកមុនដំបូងគ្រុនមកពីដីថៃនឹងមកដល់ ។

ឈុនលី ៖ ៩០ជាងហើយចាញ់ទៀត?

ធួក ៖ ចាញ់ ប៉ុនមិនដឹងចាញ់មិនចាញ់ ប៉ុនគ្រុននោះគ្រុន ។ គ្រុនដាក់សារ៉ូតាំងពីជើង តាំងពីខ្នង ជើងក៏ដាក់សារ៉ូដែរ ។

ឈុនលី ៖ ទៅពេទ្យណាទៅ?

ធួក ៖ ពេទ្យភូមិដូងយើង គេហៅពេទ្យភូមិដូង ។

ឈុនលី ៖ អានឹងពេទ្យអង្គភាព ហើយយ៉ាងម៉េច?

ធួក ៖ ពេទ្យរួមម៉ាខ្មែរក្រហមបណ្តោយ ម៉ាខ្មែរក្រហមនៅខាងនេះបណ្តោយ ។

ឈុនលី ៖ ចឹងបានន័យថាដូចខាងខ្មែរក្រហមដែលជម្លៀសមកនឹងចឹង គេនៅបង្កើតសហករណ៍អីចឹង មានពេទ្យមានអីរួមចឹងទៅ?

ធួក ៖ អត់មានសហករណ៍ទេ ។

ឈុនលី ៖ អូ! អានឹងគេចែករបប ត្រូវហើយ?

ធួក ៖ គេឈប់ហើយ សហករណ៍មានតែសម័យ៣ឆ្នាំ ដល់ពេលមកសម័យនេះអត់មានសហរកណ៍ទេ ។

ឈុនលី ៖ ហើយដល់ពេលចឹង ឈឺអីចឹងគេមើលអីចឹង?

ធួក ៖ ឈឺអីចឹង ទៅដេកពេទ្យ យើងប្រពន្ធទាហានៗគេអត់ថាអីទេ ដេកទៅ ។

ឈុនលី ៖ ចុះបើប្រជាជនដូចគ្នាដែរ?

ធួក ៖ ប្រជាជនៗក៏ទៅដូចតែគ្នា ។

ឈុនលី ៖ យើងនៅរួមគ្នា?

ធួក ៖ ហ្នឹងហើយ ព្រោះអីយើងវាគ្មានពេទ្យពីណាផង មានឃើញតែនឹងមួយទៅអត់អីទេ ពីព្រោះភាគច្រើនដូចជាគ្មានប្រជាជនៗតែប្ដីទៅធ្វើទាហានដូចគ្នា គ្មានអ្នកណានេះ ។ ពិតមែនថាប្រជាជនមែន តែបានជាគ្រួសារក៏ប្ដីទៅធ្វើទាហានដូចតែគ្នា ។

ឈុនលី ៖ ហើយចឹងដូចអ៊ំខស្សរាហ៍ទៅលេងស្រុកកំណើតដែរ ឥឡូវនឹង?

ធួក ៖ ទៅឲ្យតែ ។

ឈុនលី ៖ ស្រុកអីគេនឹង?

ធួក ៖ ស្រុកខាងមង្គលបូរី ។

ឈុនលី ៖ ឃុំអីគេទៅពីដើម?

ធួក ៖ .....ស្រុកមង្គលបូរី ចុះទៅម៉ាជួរផ្សារ តែចុះទៅក្រោមតាមជងស្ទឹង ។

ឈុនលី ៖ ដូចថាគាត់នៅខាងនេះមង្គលបូរី គាត់នៅជិតដែរ?

ធួក ៖ មង្គលបូរី ខ្ញុំនៅនិមិត្ត នៅឃុំយាង ។

ធានី ៖ មីងនៅមង្គលបូរី មីងនៅតាំងពីពេលណា?

ធួក ៖ មង្គលបូរី នៅតាំងពីនៅតូចៗដូចថាម្ដាយអីយើងនៅតូចៗប៉ុននេះ ដល់តែពេលធំតិចស្រុកភូមិយើងក៏មាន តែដូចថាម៉ែឪយើងគាត់មកចាប់ដីនៅម៉ាជួរឃុំយាងនេះ គេហៅដើមពោធិ៍៣ដើមនេះ ចាប់ស្រែ ។

ឈុនលី ៖ ពោធិ៍៣ដើម?

ធួក ៖ ពោធិ៍៣ដើម ហ្នឹងហើយមកចាប់តាំងពីឆ្នាំ៦៩ ៦៨នោះ ។

ធានី ៖ ចឹងមីងអ្នកស្រុកនេះយូរហើយ?

ធួក ៖ អ្នកស្រុកនេះយូរហើយ តាំងពីក្មេងៗ ។

ធានី ៖ មីងដឹងថានៅនឹងគេហៅតំបន់អី កាលសម័យ៧៥ សម័យ៣ឆ្នាំ?

ធួក ៖ សម័យ៣ឆ្នាំនៅនោះវិញ នៅកូនដំរីនៅនោះវិញ ។

ឈុនលី ៖ ចឹងបានដូចថាយើងមកចាប់ដីទុកចោលនៅនឹង ហើយយ៉ាងម៉េច?

ធួក ៖ តាមមើលលោកពុកអីគាត់មកចាប់ ពីព្រោះនៅមង្គលបូរីនោះ អត់មានដូចថាមានតែផ្ទះ មានតែអី តែស្រែអត់ឃើញមានទេ ។

ឈុនលី ៖ អូ! ប្រហែលជាគាត់អាចចាប់ធ្វើស្រែ?

ធួក ៖ ដល់ចឹងយើងមកចាប់ស្រែនៅនេះវិញៗ ដល់ពេលបងធ្វើការយើងប្ដូរមកនៅនេះវិញ ។

ធានី ៖ នៅណាវិញ?

ធួក ៖ មកនៅនិមិត្ត មកនៅឃុំយាង ។

ឈុនលី ៖ និមិត្តជាអីគេ ជាស្រុក ជាអីគេ ជាឃុំ?

ធួក ៖ និមិត្តនឹងស្រុកតើ ស្រុកនិមិត្ត តែដល់ក្រោយទៀតមីងមិនដឹងទេ ព្រោះអីយើងមកសម័យនឹង ។

ឈុនលី ៖ កាលនឹងខេត្តបន្ទាយមានជ័យដែរ ស្រុកនិមិត្ត?

ធួក ៖ ហ្នឹងហើយ ស្រុកនិមិត្ត ។

ធានី ៖ មីងថានៅកូនដំរីនៅស្រុកអី កាលសម័យ៣ឆ្នាំ?

ធួក ៖ ស្រុកអី ។

ឈុនលី ៖ គេហៅស្រុកអី?

ធួក ៖ ស្រុកនិមិត្តនឹង ។

ធានី ៖ ស្រុកលេខប៉ុន្មាន?

ឈុនលី ៖ កាលនឹងគេមានចែកលេខតំបន់ប៉ុន្មាន ស្រុកប៉ុន្មាន?

ធួក ៖ ទេ! មីងមិនសូវដឹងទេ ពីព្រោះកាលនោះមីងនៅក្មេងដែរ នៅអាយុ១៣ឆ្នាំ នៅអាយុ៨ឆ្នាំ ១៣ឆ្នាំ ១៨ឆ្នាំ ដល់ចឹងយើងមិនបានគិតអារឿង ។

ឈុនលី ៖ ស្រុកកំណើត?

ធួក ៖ ស្រុក យើងដឹងស្រុក យើងដឹងតែភូមិយើង តែត្រង់ថាគេចែកឃុំអីយើងអត់សូវដឹងទេ ។

ឈុនលី ៖ អ្នកគ្រប់គ្រងអីចឹងនៅនឹង?

ធួក ៖ អូ! ពីសម័យណា?

ឈុនលី ៖ អាឡុង់ពន្លឺ ដូចខាងតំបន់នេះ ឬមួយខាងតំបន់ដែលអ៊ំនៅអីចឹង អ្នកគ្រប់គ្រងអ្នកណាអ្នកដឹកនាំ?

ធួក ៖ សម័យពន្លឺស្គាល់ វាមានដូចថាវាមានមេកងក្តាប់យើងទាំងអស់ យើងមានកងតូចកងធំ ។

ធានី ៖ មីងស្គាល់មកពីខាងណាក្តាប់ទាំងអស់?

ធួក ៖ ក្តាប់ទាំងអស់ពូភាព១ យើងនេះ គាត់ក្តាប់ម៉ានិមិត្តនឹង ប្រុស១ក្តាប់ទាំងអស់ ។

ឈុនលី ៖ ឆ្នាំណាទៅ?

ធួក ៖ ពីសម័យដូចថាឆ្នាំ ។

ធានី ៖ វៀតណាមចូលនៅ?

ធួក ៖ ៧៨ហ្នឹង ។

ធានី ៖ ៧៨ ឬក៏យួនចូលហើយ?

ធួក ៖ ពីព្រោះអ្នកធំមិនមែនក្តាប់តែនេះណា អ្នកធំដូចថាមុនដំបូង៧៥អ្នកធំផ្សេង ដល់តែ៧៦ ៧៧អ្នកធំផ្សេងទៀត ។

ឈុនលី ៖ ៧៥នឹងអ្នកណាគេដែលធំនៅនេះ?

ធួក ៖ ៧៥នឹង ពីព្រោះអីមីងមិនសូវស្គាល់គេទេ ពីព្រោះបានថាមិនសូវស្គាល់ សម័យនឹងមីងនៅក្មេង១ពីព្រោះរបបនឹងវាខ្មែរក្រហមគេឡើងមកពីព្រៃគេមកក្តាប់យើងវិញ ។ ហ្នឹងហើយដល់អ្នកនៅពីសន្តមចាស់គេវៃចោលវៃទៅយើងម៉េចដឹង ដល់ហើយឡើងខ្មែរក្រហមមកវិញហើយ ។

ឈុនលី ៖ យើងចូលជាមួយគេបណ្តោយ?

ធួក ៖ អឺ!

ធានី ៖ មីងស្គាល់ទេ ខ្មែរក្រហមមកពីព្រៃ ស្គាល់ឈ្មោះគាត់?

ធួក ៖ ស្គាល់ឈ្មោះភាព ។

ឈុនលី ៖ តាភាពនឹង?

ធួក ៖ ភាពនឹងភាពតូច មាឌល្អិតទេ ។

ឈុនលី ៖ មិនមែនសុខ ភាពទេ?

ធួក ៖ ភាពនឹងមកពីស្រែអំបិល ។

ឈុនលី ៖ មិនមែនសុខភាពនេះទេ?

ធួក ៖ អត់ទេ ។

ធានី ៖ ស្រែអំបិលភូមិភាគអីគេ?

ដូក ៖ មីងមិនស្គាល់ទេ ដឹងថាស្រែអំបិល ។

ឈុនលី ៖ ស្រែអំបិលខាងកំពតនឹង?

ដូក ៖ ហ្នឹងហើយ ពូភាព ហើយដល់ពេលមកឆ្នាំ៧៨ ៧៧បានឃើញពូភាពយើងនេះ ពូភាពខ្ពស់នឹង ។

ឈុនលី ៖ សុខ ភាព?

ដូក ៖ អឺ! ហ្នឹងគាត់មកម្ដង ។

ធានី ៖ ហ្នឹងគាត់មកជំនួស ភាពចាស់នឹង ភាពតូចល្អិតនឹង?

ដូក ៖ ហ្នឹងហើយ ។

ឈុនលី ៖ ហើយភាពនេះមកពីណាវិញ?

ដូក ៖ មិនសូវដឹងទេ ។

ធានី ៖ អ្នកស្រុកនឹងទេ?

ដូក ៖ យើងមិនសូវដឹងទេ ពីព្រោះយើងអត់សូវដឹង ។

ឈុនលី ៖ ហេតុអីបានបាត់ពូភាពចាស់នឹងទៅណា?

ដូក ៖ ទេ!.... យើងអត់សូវដឹង ពីព្រោះអីវារបបនឹងថាគេថាក្បត់ មិនដឹងថាគេជម្លៀសទៅណា មិនដឹងថាគេយ៉ាងម៉េច យើងអត់សូវដឹងទេ ពីព្រោះយើងនៅកូនគេយើងម៉េចសូវដឹង ។

ធានី ៖ មីងមានដឹងថាភាព ដែលមីងនិយាយថាភាពតូចល្អិតនឹង ភាពនឹងគាត់អ្នកគ្រប់គ្រងម៉េច គាត់គ្រប់គ្រងនៅសហករណ៍មីង ឬក៏គ្រប់គ្រងធំនៅនឹង?

ដូក ៖ គ្រប់គ្រងនារី យុវជន ។

ធានី ៖ គ្រប់គ្រងនារី យុវជន ស្រីចឹង ភាពនឹង?

ដូក ៖ ប្រុស ។

ឈុនលី ៖ តែកាន់ខាងយុវជន នារី?

ដូក ៖ ហ្នឹង! យុវជន នារីដូចថាយើងយុវជន ។

ធានី ៖ ចុះធំជាងភាពនឹងមីងស្គាល់?

ដូក ៖ ពីព្រោះយើងមិនបាន យើងនៅតូចជាងគេ យើងដឹងថាធ្វើការយើងមិនបានទៅប្រជុំនឹងគេឲ្យឃើញអ្នកនេះអ្នកនោះណា យើងនៅកូនគេ ។

ធានី ៖ ហើយមីងដើរទៅធ្វើការណាខ្លះ?

ដូក ៖ អឺ! ក្មួយអើយ អារឿងធ្វើការៗនោះរាល់តែថ្ងៃសម័យនោះ ។

ធានី ៖ ចា៎! ធ្វើការណាខ្លះ?

ធួក ៖ ធ្វើការម៉ុំគោកធំ យើងមកតាំងពីនិមិត្ត មកលើកប្រឡាយមកស្ទួងនៅគោកធំនេះ ដូនកាលមកនៅគោកធំ ។

ធានី ៖ គោកធំនៅណាវិញ?

ធួក ៖ គោកធំយើងនេះ គេហៅគោកធំនេះ ។

ធានី ៖ ក្បែរខ្វាងសាប់ទេ?

ធួក ៖ អូ! មកពីកូនដីវិតិចមក ។

ធានី ៖ ចុះម៉ក់ហឺន ក្បែរម៉ក់ហឺន?

ធួក ៖ ម៉ក់ហឺនទៅពីនេះវិញ ។

ឈុនលី ៖ ម៉ក់ហឺន ជាទំនប់ អឺ!ជាអីគេ តំបន់?

ធានី ៖ មីងធ្លាប់ធ្វើការនៅម៉ក់ហឺនអត់?

ធួក ៖ ទេ!

ធានី ៖ អត់ដែរ ត្រឹមគោកធំ?

ឈុនលី ៖ តែអាជំនាន់នឹងដែលឮឈ្មោះអត់ ដែលឮឈ្មោះម៉ក់ហឺនអត់?

ធួក ៖ ពីសង្គម ។

ឈុនលី ៖ អានឹងជាកន្លែងអីគេចុះ?

ធួក ៖ ម៉ក់ហឺន ដូចជាកន្លែងគេចាប់ដីថ្មី គេបង្កើតដីថ្មីដូចឆ្នាំ៧៨ ឬក៏៧៣ចឹងទៅ គេប្រកាសណាមានដីចឹងទៅមកចាប់ម៉ក់ហឺន ។ ហ្នឹងដល់ពេលចាប់ទៅដូនកាលអ្នកណាគេលក់ៗ អ្នកណាគេនៅក៏នៅទៅបង្កើតជាសហគមន៍ ។

ធានី ៖ ក្រៅពីម៉ក់ហឺនមានកន្លែងផ្សេងទៀត មានស្រុកណាជាប់ម៉ក់ហឺន?

ធួក ៖ គ្មានណា មានតែខ្វាងសាប់មកវិញ ។

ធានី ៖ ខ្វាងសាប់ មានអ្នកណាគេនៅ?

ធួក ៖ ទេ! មិនសូវដឹងទេ ពីព្រោះអីយើងអត់សូវដឹង យើងអត់សូវដឹងយើងនៅតូច ។

ឈុនលី ៖ ចុះបើគិតទៅនៅម៉ក់ហឺននឹងមានប្រជាជនគាត់ធ្វើស្រែធ្វើអី?

ធួក ៖ មាន ។

ឈុនលី ៖ ចុះជំនាន់៣ឆ្នាំ?

ធួក ៖ ជំនាន់៣ឆ្នាំ មិនដឹងថាគេទៅណាមកណាយើងអត់ដឹង យើងមានតែឈ្មោះម៉ក់ហឺន តែមានតែផ្ទះចាស់គេ មានស្រះគេ តែមិនដឹងមនុស្សទៅណាអស់អត់ដឹងទេ ។ គេទៅស្រុកទៅភូមិគេអស់ ។

ឈុនលី ៖ ចុះក្នុងពេលនឹងអ៊ំដែលពុកទំនប់ម៉ក់ហឺននឹងអត់?

ធួក ៖ ពុក ។

ឈុនលី ៖ ចឹងបានន័យថាមានទំនប់ហើយ?

ធួក ៖ ទំនប់ទេ! ទំនប់នឹង អ៊ំមិនសូវដឹងកន្លែងម៉ក់ហឺន ប៉ុន្តែត្រង់ទំនប់ត្រង់អីអត់សូវដឹង ពីព្រោះយើងមិនបានមកខាងនេះណា យើងដឹងថាពីសង្គម ដល់ពេលសម័យ៣ឆ្នាំយើងមិនបានមកខាងម៉ក់ហឺនណា យើងនៅខាងកូនដីរ៍ ខាងគោកធំនោះទេ ។

ឈុនលី ៖ ចុះបើគិតទៅម៉ក់ហឺនចូលទៅខាងស្រុកម៉ាឡៃ?

ធួក ៖ អឺ! ម៉ក់ហឺន ។

ឈុនលី ៖ បើយើងទៅពីនេះជិតម៉ក់ហឺន ចេញពីម៉ក់ហឺនបានទៅខ្វាងរាប់?

ធួក ៖ ចេញពីខ្វាងរាប់អីទៅចឹងទៅៗជិតដល់គោកធំដូចថាពីម៉ក់ហឺនទៅគោកធំបណ្ដោយ ។ តែដល់គេធ្វើផ្លូវធ្វើអី យើងក៏មិនដឹងថាផ្លូវនឹងគេយកកន្លែងម៉ក់ហឺនមិនដឹង ។

ឈុនលី ៖ ចុះអ៊ំដឹងថាគោកធំ គោកតូចនឹង ឥឡូវវាជាអីគេ ជាភូមិជាឃុំ ឬក៏ជាអី?

ធួក ៖ ហ៊ើ! អត់ដឹងទេ ពីព្រោះមករបបនេះយើងអត់សូវដឹង យើងដឹងថាពីមុនដល់ពេលមកដល់របបថ្មីយើង ។ មើលលើកមុននិមិត្តមានតែមួយ មកពីកូនដីរ៍ហៅនិមិត្ត ដល់ឥឡូវនិមិត្ត១ និមិត្ត២ និមិត្ត៣ ដល់ចឹងខ្ញុំអត់ដឹង ។ យើងធ្លាប់ដឹងពីសម័យមុន ដល់មកសម័យក្រោយយើងអត់ដឹង ជឿទេក្មួយ?

ឈុនលី ៖ ចា៎! ត្រូវហើយ ។

ធួក ៖ ហ្នឹងហើយ ខ្ញុំអត់ដឹង ។

ឈុនលី ៖ ណាមួយយើងនៅតែខាងក្នុង?

ធួក ៖ ហ្នឹងហើយយើងនៅតែនេះ យើងអត់ដឹងនិមិត្ត១ និមិត្ត២ យើងអត់ដឹង យើងដឹងថាធ្លាប់តែនិមិត្ត ពីដើមមិញនិមិត្តគោកតូច ។ ដល់មកឥឡូវវាចូលនិមិត្ត១ និមិត្ត២ ។

ឈុនលី ៖ ចុះអ៊ំដល់ពេលគេសមាហរណកម្មអីចឹង ពេលនឹងឪពុកម្ដាយរបស់អ៊ំដឹងទេបងប្អូនអីគាត់ដឹងទេ ថាអ៊ំនៅនេះ?

ធួក ៖ ដឹង យើងទៅលេង ។

ឈុនលី ៖ ពីអង្កាល់?

ធួក ៖ ឆ្នាំ៩៣ ។

ឈុនលី ៖ តែមុន៩៣ គាត់ដឹង?

ធួក ៖ ឆ្នាំ៩៣យើងដឹងដែរ ពីព្រោះអីយើងស្រុកភូមិយើងចាស់ ដល់ពេលយើងមកចេះយើងអាច សួរអ្នកណាដែលគេចេញចូលបានដឹងថានៅនឹងដែរ តែយើងទៅមិនរួច ។

ឈុនលី ៖ គេអត់ឲ្យយើងចេញទេ?

ធួក ៖ យើងចេញបាន ប៉ុន្តែដូចថាយើងចេញ.....ត្រង់ថា.........យើងចេញទៅ ។

ឈុនលី ៖ គេថាយើងទៅយកការយកអី?

ធួក ៖ ដល់ចឹងយើងមិនសូវបានចេញទេ ។

ឈុនលី ៖ ចឹងធ្វើម៉េចបានឲ្យដំណឹងទៅខាងម្ដាយឪពុកបាន?

ធួក ៖ មានគេអ្នកខ្លួនមួយអីចឹង គេទៅមកចេញចូលដូចថា បងប្អូនយើងជួនកាលមានមកដែរ មាន មកចឹងយើងចេះសួរណា ។ ហើយកាលដែលពួកអ្នកនៅព្រៃខាងនោះ នឹងខាងនេះមិនដែល ត្រូវគ្នាផង ត្រូវគ្នាខ្លះ មិនត្រូវគ្នាខ្លះ បើប្រជាជនត្រូវគ្នាម៉ង ។ ប្រជាជនមកលក់អង្ករឲ្យ ខ្មែរក្រហម ។

ឈុនលី ៖ ខាងក្នុងលក់ឲ្យវិញ ចុះម៉េចខ្មែរក្រហមទិញគេ បើយើងមានរបប?

ធួក ៖ មានរបប យកទៅមិនរួច វាឆ្ងាយ ពីព្រោះយើងមិនមែនថ្នល់ទៅរហូតណា មិនដូចសព្វថ្ងៃ ណា វាតាមព្រៃតាមឯស្រែយើងទៅមិនរួចណា ។ ម្លេះហើយយើងទៅនោះយើងទិញនោះ វាយកមកលក់ នោះគេយកមកលក់វាបានថ្លៃ ជឿទេក្មួយ ។ ហ្នឹងហើយវាបានថ្លៃ ដល់ចឹង ហើយប្រជាជនចេះយកលួចយកទៅលក់ណា មិនទៅស្រួលៗទេ លួច ។

ឈុនលី ៖ ខាងយើងអ្នកលក់ទេ?

ធួក ៖ ចេះលួចយកទៅលក់.................ចុះយើងយកមកលក់ឲ្យខ្មែរក្រហម ។

ឈុនលី ៖ ហើយកាលនឹងខ្មែរក្រហមមានលុយទិញដែរ?

ធួក ៖ មាន គេអ្នកធំគេមាន បើយើងអ្នកតូចតាច ដែលមាន យើងមាន ។

ឈុនលី ៖ អានឹងគេទិញដើម្បីអី យកមកចែកគ្នាតើ?

ធួក ៖ អឺ! យកមកចែកពួកទ័ពនឹង ។

ឈុនលី ៖ ចែករបបដូចខាងទ័ព?

ធួក ៖ ហ៎! គេចែកហ្នឹងហើយ ដូចថាយើងទៅនៅមុខប៉ុន្មានចឹងម៉ាក្រុមគេនឹង គេទិញបានគេហូប នោះទៅ ។ អាប្រជាជននៅនេះ គេចែកនេះផ្សេង ពីព្រោះយើងយកទៅពីនេះមានរួចណា វាភក់ វាទឹកនោះ ។

ឈុនលី ៖ បើគិតទៅចំងាយពីណាមកនេះ ពីកន្លែងខ្មែរក្រហមចាំត្រៀម ហើយមកដល់នេះតើប៉ុន្មាន គីឡូ?

ធួក ៖ ទេ! ឯងនោះខបមាថាគោកគួច ខ្មែរក្រហមវាទៅម៉ាដួរគាគង់ ម៉ាដួរចែងមែងនោះ ដែលស្គាល់ទេក្មួយ ។

ឈុនលី ៖ ចែងមែងធ្លាប់តែឮ អត់ដែរស្គាល់ ។

ធួក ៖ អឺ! ខ្មែរក្រហមនៅនោះ ហើយដល់ពេលអ្នកគោកគួចគេប្រជាជនគេមិនទូលអង្គរនឹងទៅព្រៃនោះវិញ ។ ទៅនោះវិញទៅ បើឯងនេះគ្មានទាក់ទាមអីទេ ឯងនេះវាឆ្ងាយផង ។

ឈុនលី ៖ យើងមានតែយើងនៅធម្មតា ពួកអ្នកទ័ព?

ធួក ៖ ហ្នឹងហើយនៅធម្មតា ។

ឈុនលី ៖ ចឹងកាលនោះអ៊ំទោះបីយ៉ាងណាហូបចុកអីគ្រប់គ្រាន់ដដែល?

ធួក ៖ ចេះតែហូបទៅក្មួយអើយទោះបីស្ងួដាក់បន្ទែនឹងយើងចេះតែហូបទៅ ចុះត្រីខម៉ាកំប៉ុងគេឲ្យម៉ាខែក្នុងម្នាក់ បើយើង៣នាក់ ២នាក់គេឲ្យ២កំប៉ុង ហើយក្មួយឯង ។

ឈុនលី ៖ ហូបអត់គ្រប់?

ធួក ៖ ហូបម៉េចគ្រប់ យើងចេះតែស្ងួទៅ យើងមានទិញគេទៅ ហើយប្តីដួនកាលឆ្មៀតអាឈើអាអីលក់ឲ្យថៃទៅ ។

ឈុនលី ៖ ចុះដូចអ៊ំធ្លាប់ឆ្លងកាត់យូរហើយ អ៊ំគិតថាមកដល់សម័យនេះ អ៊ំគិតថាមួយណាវាប្រសើរជាង ព្រោះកាលលើកមុនយើងមានម្ហូបស្រាប់ទៀត?

ធួក ៖ អឺ!ក្មួយអើយវាមិនដូចសម័យនេះទេ បើសិនណាដូចអ៊ំចឹងបើសម័យមុន បើអ៊ំដឹងថាសម័យវាសប្បាយ មានឡានមានម៉ូតូ ហូបចុកឯកជន អ៊ំមិនមកនេះទេ ។ តែយើងមិននឹកស្មានចឹងពីព្រោះយើងធ្លាប់សម័យ៣ឆ្នាំយើងបាក់សម័យ៣ឆ្នាំ ។ ម្ល៉េះហើយបើដឹងថាស្រួលចឹង ម៉ែឪបងប្អូនខ្ញុំឯង មិនមកទេ សុខចិត្តនៅប៉ុនពេលនឹងយើងនៅនារីនោះ ហើយដល់គេថាកុំទៅយួនចូលអា-ក ។

ឈុនលី ៖ គេបន្លាចយើង?

ធួក ៖ អើ! ដល់ចឹងយើងនៅក្មេងៗយើងចេះមកៗ ដល់ពេលទៅវិញទៅម៉េចរួច ដល់ម្នាក់កាន់កាំភ្លើង ពីតំបន់មួយទៅតំបន់មួយ ។ បើថាដឹងថាយើងដល់ពេលឆ្នាំ៩៣ ទៅស្រុកឃើញបងប្អូនអីគេនៅជុំគ្នារកស៊ី នឹកឃើញអត់ចិត្តថា អឺ! បើសិនណាជាបើដឹងថាចឹងអត់មកទេ ។

ឈុនលី ៖ ស្តាយក្រោយ?

ធួក ៖ ស្តាយ ប៉ុនធម្មតាទោះបីយើងនៅរបបខ្មែរក្រហមហើយក៏ដោយ តែយើងក៏មិនចូលចិត្តដែរតែយើងមិនដឹងធ្វើ តែមិនដឹងអ្នកណាគេចូលចិត្ត អានឹងមីងមិនដឹងទេ ។ តែចំពោះមីងមួយមីងមិនចូលចិត្តទេ ប៉ុន្តែយើងវាមិនដឹងធ្វើម៉េច ដូចថាយើងនៅជានារីហើយ គេជម្លៀសមក

ហើយ គេមានគេជិះសេះតាមសម័យ ដែលកាលទាហានខាងនេះចូលមកគេបាញ់អី ដូចថា យើងចូលមកគេបាញ់អីនឹង ដូចថាយើងរត់នារីៗមកយើងរកទៅក្នុងគេជិះសេះតាម គេកៀងយើងអត់ឲ្យយើងទៅទេ ។

ឈុនលី ៖ ហើយដល់ពេលទៅលេងស្រុកវិញ អ្នកជិតអ្នកខាងអីចឹងគេ យ៉ាងម៉េច?

ដួក ៖ មានអីបងប្អូនស្គាល់គ្នា អ្នកស្រុកអ្នកភូមិធម្មតា ។

ឈុនលី ៖ ចុះគេអត់គិតថាមីង?

ដួក ៖ ខ្មែរក្រហម ។

ឈុនលី ៖ ហ្អឹងហើយខ្មែរក្រហម?

ដួក ៖ អត់ទេ មិនគិតដូចមិនមានចិត្តចឹងទេ ប៉ុនដូចថាយើងថាមិនត្រូវដែរ ប៉ុនណាយើងមើលម៉ាដុំ ដែលបងប្អូនយើងអីគេដូចមិនគិតវែងមិនគិតឆ្ងាយទេ ពីព្រោះសម័យនឹងវាខ្មែរក្រហមទាំងអស់ ខាងនោះក៏ខ្មែរក្រហមដូចគ្នា ។ តែគ្រាន់ថាវាមានបែកគ្នា ដូចថាវាមានបក្សពួក ។

ឈុនលី ៖ គ្រាន់ថាគេឆាប់ចូលស្រុកវិញ?

ដួក ៖ អឺ! គេឆាប់ចូលស្រុកមុន អាយើងនៅឆ្ងាយទៅវាចេះអណ្ដែតអណ្ដូងទៅណា ។

ឈុនលី ៖ ដូចអីក៏មិនពេញចិត្តដែរ ពេលនឹងជាមួយខ្មែរក្រហម?

ដួក ៖ មិនពេញចិត្តដែរ តែមិនដឹងធ្វើម៉េច ។

ឈុនលី ៖ ហើយដល់ពេលយើងចូលស្រុកដំបូង យើងមានអារម្មណ៍ថារអៀសខ្លួនទេ?

ដួក ៖ ទេ! អត់មានគិតចឹងទេ គិតថាធ្វើម៉េចទៅជួបបងជួបប្អូន ។

ឈុនលី ៖ អ្នកណាថាអីថាទៅ?

ដួក ៖ ទេ! មិនមានគិតថាម៉េចៗទេ អត់មានគិតទេ គិតថាធ្វើម៉េចទៅជួបបងជួបប្អូន ដូចគ្មានចិត្តថាយ៉ាងម៉េចមួយអត់ ។

ឈុនលី ៖ គេនោះក៏ល្អជាមួយយើងដែរ?

ដួក ៖ បងប្អូនអត់មានអីផង ពីព្រោះអីវាដូចថាវាភាគច្រើន យើងវាមកនឹងវាទីណាត់ទីណែងយើងវានៅក្មេងៗវាចេះអណ្ដែតអណ្ដូងនឹងគេទៅណា ។ ដល់ចឹងទៅយើងទៅវាមិនរួច..........ដូចថាយើងមិនទាន់បានគ្រួសារ តាំងតែខឹងខ្មែរក្រហមសឹងតែយកប្ដីជាខ្មែរក្រហម ស្អប់គេជម្លៀសយើង ។ ដល់ពេលមកចឹងវាខ្មែរក្រហមទាំងអស់ តាមតែខឹងមិនយកទេ អាប្ដីខ្មែរក្រហមគេជម្លៀសឯង កាលគេជម្លៀសអឹនៅក្មេងៗអាយុ១៨-១៥ ខ្មែរក្រហមជម្លៀសនឹងឯង សូម្បីតែនែក!មិត្តបងសម័យនឹងគេហៅមិត្ត មិត្តបងឲ្យខ្ញុំសុំជាំបាយហូបសិន? អត់បានទេ ទៅទៀត ឲ្យទៅតាពូងនោះៗឆ្ងាយណាស់ ។ ដែលស្គាល់?

ឈុនលី ៖ តាពូង អត់ដែលព្រួដង ។

ធួក ៖ តាពូងឆ្ងាយណាស់មើលទៅអត់មានឃើញដើមឈើទេ ។

ឈុនលី ៖ អានឹងខេត្តអី នៅណា?

ធួក ៖ បាត់ដំបង តាពូងៗ ។

ឈុនលី ៖ បាត់ដំបង ចឹងបានន័យថារត់មកដំបូង?

ធួក ៖ អានឹងគេជម្លៀស និយាយពីជម្លៀស ។

ឈុនលី ៖ ចា៎! ជម្លៀសចូលទៅបាត់ដំបងហើយ បានវៀងមកដល់នេះ?

ធួក ៖ អត់ទេ គេចូលមកយើងជម្លៀសទៅម៉ាដួរឆាយ ។ ដែលស្គាល់ឆាយ ម៉ាដួរក្រោយគោក តូចយើងនេះ ។

ឈុនលី ៖ មិនសូវដែលស្គាល់?

ធួក ៖ ដល់ពេលក្រោយទៀត គេជម្លៀសទៀត គេចាប់ផ្ដើមទៅជ្រោយម្ទេសថ្មគោលនឹង ដល់ចឹងគេឲ្យទៅខាងតាពូង បានគេហៅពីតាពូងនឹងមកធ្វើដីកជញ្ជូននេះវិញ ខឹង.......... ។

ឈុនលី ៖ មកចូលនឹងដែរ?

ធួក ៖ ហើយសម័យ៣ឆ្នាំ.................យើង១៧មេសាចឹងយើងថា.................................. អ្នកតស៊ូជួនកាលគេអត់ចឹងនិយាយរកយើងទេ ។

ឈុនលី ៖ ពេលដែលអ៊ំចូលដំបូងដូចអ៊ំចឹង?

ធួក ៖ គេចែកគ្នាដូចថាសម័យនោះ អ្នកណាដែលតស៊ូគេនៅម៉ាកងគេផ្សេង នៅម៉ាក្រុមគេផ្សេង ហើយយើងអ្នកកូនប្រជាជនដូចថាយើងនៅចេះចុះ គេយកទៅធ្វើនារីដូចអ៊ំចឹង យើងនៅម៉ាក្រុមគេផ្សេង នៅម៉ាកងគេផ្សេង ម៉ាវរៈផ្សេង អត់មាននៅច្របូលច្របល់ទេ ដល់ក្រោយមកបានគេយកកម្លាំងមកក្ដាប់យើង ដូចមេក្រុមក៏គេក្ដាប់យើង កងតូចក៏គេក្ដាប់យើង អ្នកតស៊ូ ។ ហ្នឹងហើយដល់ពេលយើងដើរទៅធ្វើការចឹង ជួនកាលយើងខោអាវយើងក្រណាត់ប្រឡាក់ពណ៌សទៅស្ងួងទៅដក ដីវាកាន់វាចាស់វាក្រហម ស្មើជន្លង់ ហើយដៃអាវជួនកាលវារហែក ចុះវាផុតដែលយើងស្ងួងនោះ វាពុកវាផុយ ។ ហើយមានតែ២កំប្លេអីនឹង ៣កំប្លេដល់ចឹងទៅយើងហែកទៅតអាវអាត្រង់នេះទៅឡើងក្រហម ហើយពេលណាដូចអ៊ំចឹង ពេលណាដើរជិតទ័ពអីចឹង ហើយបើទ័ពគេស្អាតខោអាវគេខ្មៅ កន្សែងគេចឹងខ្លួនគេចឹង...គេអ្នកតស៊ូ តែយើងអ្នក១៧មេសា ជួនកាលយើងមិនសូវហ៊ាននិយាយរកនឹងគេទេ......... ។

ឈុនលី ៖ អត់និយាយលេងជាមួយយើងអីទេ?

ធួក ៖ ......តឹងតែងណាស់ បើជិតរត់នេះតឹងតែងមែនទែន សូម្បីតែបងប្អូនបង្កើតអត់ឲ្យនិយាយរកគ្នាទេ ។

ឈុនលី ៖ អានឹងឆ្នាំណាទៅ?

ធួក ៖ ឆ្នាំ៧៨ ៧៩ដែលជិត១ ។

ឈុនលី ៖ ជិតៗពេលវៀតណាមចូលនឹង?

ធួក ៖ អឺ! គេអត់ឲ្យនិយាយរកគ្នាទេ ។

ឈុនលី ៖ ហេតុអីបានពេលនឹងកាន់តែខ្លាំងឡើងចឹង?

ធួក ៖ ទេ! មិនដឹងម៉េចដល់ចឹង គេអត់ឲ្យនិយាយរកគ្នា........ ។

ឈុនលី ៖ ហើយឃើញចេះ....?

ធួក ៖ ហើយបើអង្គុយ២នាក់អត់ឲ្យអង្គុយទៀត គេឲ្យខ្លាចយើងជំនុំគ្នា ។

ឈុនលី ៖ .....របប?

ធួក ៖ អឺ! អត់ឲ្យអង្គុយទេ គេឲ្យអង្គុយពីពនាក់ឡើងទៅ ។ ហើយបងប្អូនមកលេង បើបងប្អូនមកលេងប្រុសចឹង ដូចថាគេនៅកងផ្សេងចឹង គេមកលេងបងប្អូនចឹង ចង់ជួបប្អូនចឹងគេអត់នៅយូរចឹងទេ ហើយគេប្រាប់ឲ្យថា...................................... ។

ឈុនលី ៖ គិតទៅវាពិបាកដល់?

ធួក ៖ ......................... ។

ឈុនលី ៖ ចុះរហូតដល់ពេលស្រួលបួល អ៊ំនៅមានពិបាកពេលដែលយើងត្រូវរវូវគ្នាហើយ?

ធួក ៖ អត់ ត្រូវរវូវគ្នាហើយអត់មានពិបាកអីទេ យើងធ្វើស្រែ ធ្វើចំការធម្មតា ដែលយើងមានប៉ុននឹងឯង បើពីសម័យពឆ្នាំយើងពិបាក១ ដែលយើងខ្លួនមួយយើងមិនភ័យថាខ្លាចកូនយើងអត់ស៊ី យើងអត់មានកូន ទោះបីកន្ទុះកំប៉ុងក៏យើងហូបឆ្អែត ម៉ាកំប៉ុងក៏យើងហូបឆ្អែតដូចថាយើងទប់ទល់ខ្លួនយើង ហើយម្យ៉ាងយើងនៅនឹងប៉ះកន្លែងគេស្រួលដែរ ដូចថាគេវាមិនចិត្តអាក្រក់ពេក ដូចថាក្រុមយើងកងយើងវាអត់ចិត្តអាក្រក់ពេក............ ។

ឈុនលី ៖ ចុះដូចអ៊ំគិតថាមកដល់សព្វថ្ងៃនឹង ប្រជាជនយើងដូចថាគាត់ដូចថាខឹងជាមួយខ្មែរក្រហមអីទេចឹង?

ធួក ៖ មិនដឹងដែរ អ៊ំមិនសូវដឹងដែរ ប៉ុនយើងមិននិយាយប្រាប់អ្នកណា ។

ឈុនលី ៖ អត់ហ៊ានប្រាប់ថាយើងខ្មែរក្រហម?

ធួក ៖ អត់បានិយាយថាយើងស្អប់ខ្មែរក្រហម យើងអត់និយាយ គឺយើងពេញចិត្តមិនពេញចិត្ត ក៏ដោយ យើងនៅនឹងទៅ បើយើងនៅនឹងហើយ ។ បើយើងនិយាយថាទោះបីអីចង់នៅក្នុង របបខ្មែរក្រហម ឥឡូវវាអត់ហើយ អត់មានហើយ........ ។

ឈុនលី ៖ អត់ដែរ?

ធួក ៖ តែយើងមិនដឹងធ្វើម៉េច មានទៅណា ចេះតែនៅទៅគេនឹងឯងទោះបី........................ ។ បងប្អូនជម្លៀសមិនឲ្យលុយចាយ មិនឲ្យមានផ្សារ បំបែកម៉ែបំបែកកូនក៏យើងដឹង ណាស់ តែយើងវានៅក្នុងរបបនឹង ហើយយើងចេះធម្មតាហើទៅ ប៉ុនចិត្តយើង..... ។

ឈុនលី ៖ គិតតាមនឹងដែរ?

ធួក ៖ ..........យើងមិនដឹងធ្វើម៉េច ពីព្រោះយើងដឹងថាខ្មែរក្រហមវាអាក្រក់ចឹងហើយ តែយើង គេចវាមិនរួច ។

ឈុនលី ៖ ចុះអីពីដំបូងមកដឹងថាខ្មែរក្រហមចិត្តអាក្រក់ ហើយចុះដល់ពេលមកនៅជាមួយខ្មែរក្រហម?

ធួក ៖ ពីដំបូងអីដឹងតាំងពីឆ្នាំ៧៥មកម្ល៉េះ ។

ឈុនលី ៖ ចាំ! ប៉ុន្តែអាក្នុងពេលដែលហើយរត់មកនៅជាមួយខ្មែរក្រហម យើងនៅជាមួយខ្មែរក្រហម អានឹងយើងដឹងថាម៉េចវិញ?

ធួក ៖ យើង ទេ!ពេលនោះយើងនៅជាមួយគេ ។

ឈុនលី ៖ យើងក៏ចូលជាមួយគេហើយ?

ធួក ៖ អឺ! គេក៏វាចូលៗតាំងពីឆ្នាំ៧៥ម៉េះនោះ ខ្មែរក្រហមតាំងពីឆ្នាំ៧៥មករហូតដល់៧៩នោះ កុំខ្មែរក្រហមទៀត ខ្មែរក្រហមរបូត តែគេក៏មិនធ្វើអីយើង ។

ឈុនលី ៖ ខ្មែរក្រហម៧៥ តែយើងធ្វើការដកស្ទូង យើងអីគេ?

ធួក ៖ អត់ទេ គ្មានដកស្ទូងទេ នៅតែដឹកជញ្ជូន ។

ឈុនលី ៖ ដឹកជញ្ជូនរហូត?

ធួក ៖ រហូត មិនដកស្ទូងទេ មកនៅនេះរហូតទាល់តែឯកជនហើយ បានដកស្ទូង គ្មានធ្វើស្រែធ្វើអ្វី ណា អត់ទេ ។ យើងនៅយូរៗទៅវាធម្មតា តែក្នុងចិត្តយើងមួយៗស្អប់ខ្មែរក្រហម ។ តែ យើងនៅខ្មែរក្រហមនឹង យើងវាយើងនៅតែមានចិត្តស្អប់មិនចូលចិត្តដែរ ពីព្រោះយើងមិន ទៅណា យើងគ្មានផ្ទះគ្មានសម្បែងទៅយើងចេះតែនៅនឹងគេទៅ ។ បើថាក្នុងចិត្តគឺយើងមិន សូវពេញចិត្តខ្មែរក្រហម.........ចូលស៊ីងតាមបត់ ។

ឈុនលី ៖ ចុះបើសិនជារហូតមកដល់សម័យបច្ចុប្បន្ន បើសិនជាមានមនុស្ស វាច្បាស់ជាមានហើយ អ្នកដែលគិតថាខ្មែរក្រហមអាក្រក់អីចឹង ហើយបើតាមអ៊ំយល់ បើសិនយើងអ៊ំផ្សះផ្សាគ្នាជា

មួយអ្នកដែលគិតថាខ្មែរក្រហមអាក្រក់នឹង ហើយអ៊ំគិតថា យើងទាល់តែរស់នៅជិតគ្នា ឬមួយក៏នៅឆ្ងាយពីគ្នា យូរៗទៅលេងម្តងបានងាយស្រួលផ្សះផ្សាគ្នា ធ្វើឲ្យថាយល់ចិត្តគ្នាអីចឹង?

ធួក : អត់កន្លែងនេះគឺអត់ហ៊ាននិយាយ ពីព្រោះអានឹងស្រេចលើចិត្តគេ យើងមិនឲ្យខ្ញុំស្អប់ខ្មែរក្រហមខ្ញុំអត់ហ៊ានថាទេ ចុះយើងនៅទឹកដីនឹងហើយយើងទៅថាធ្វើស្អី ។ ប៉ុននៅក្នុងចិត្តយើងវានៅតែមិនចូលចិត្តរបបខ្មែរក្រហមទេ ។ ប៉ុនតែយើងមិនដឹងធ្វើម៉េច វាចេះនៅចឹងហើយបើសិនណាជាអត់បានគ្រួសារ ឯងអើយ!យើងឈប់នៅនេះទៅ លក់ដីលក់ឈើ លក់ផ្ទះលក់ផ្ទះលក់សម្បែងលក់ទៅដីក្នុង អានឹងយើងអាចនៅចេះទៅៗ ។ បើយើងមិនគិតចឹងយើងមានស្រែមានចំការហើយ បើយើងទៅនោះក៏គ្មានស្រែគ្មានចំការវាលំបាក ខ្លាចយ៉ាប់អី ក៏យើងនៅនឹងចេះតែនៅទៅ ពីព្រោះយើងនៅនឹងហើយ យើងមិនបង្អាប់បន្ទោសថាយ៉ាងម៉េចៗ ប៉ុនក្នុងចិត្តយើងស្អប់ដែររបបខ្មែរក្រហមនោះ យើងស្អប់ទៅហើយស្អប់តាំងពីសម័យពន្ឋាំ ប៉ុនយើងជៀសមិនរួច ។ តែដូចថាស្អប់ចឹង ក្អួយស្អប់ចឹង អ្នកស្អប់ចេះស្អប់ហើយ តែដល់មកចឹងវាទម្លាប់ធម្មតាទៅ ។ ប៉ុនរបបនឹង ដឹងថារបបនឹងមិនចូលចិត្តដែរ ។

ឈុនលី : តែយើងមិនដឹងធ្វើម៉េច?

ធួក : ទោះបីអ្នកខ្លះនៅនោះក៏នៅមកលេង ……សម័យវៃគ្នាម៉ាវីក៩៣នៅតែមានមកអ្នកខ្លះមក …………អីចឹងមកតាមទ័ពខ្មែរក្រហម ។

ឈុនលី : មកធ្វើអី?

ធួក : មកនៅនឹង មកដូចថាគេ ។

ឈុនលី : អ្នកខ្លះមកចូលទ័ព?

ធួក : អឺ! ដូចថាគេមកលក់អង្ករមកលក់អី យើងនិយាយថាកូនប្រជាជនចុះ មកលក់អង្ករលក់អីជួនកាលនិយាយជាមួយទ័ព យើងនិយាយទៅ……ទ័ពគេនោះកំលោះ កូននោះក្រមុំអីចឹងទៅ ។……គាស់ទៅជាមួយខ្ញុំ អីក៏ខ្ញុំស្រឡាញ់អីចឹង មកទៅ ចឹងកាលគេមានម៉ែឪក៏គេមក ។

ឈុនលី : ព្រោះលែងអីហើយ លែងខ្លាចដូចពីមុន?

ធួក : ហ្នឹងហើយ ព្រោះមិនថាចិត្តអាក្រក់ចិត្តអីវា គេបើនិយាយទៅវាមានខ្ញុំអត់ដឹងចិត្តអាក្រក់វាមកពីអ្នកណាយើងវាអ្នកធំបញ្ឈាក៏យើងមិនដឹង ប៉ុនយើងតាមទ័ពយើងវាដូចមិនចិត្តអាក្រក់ទេ…..តែបើការបាញ់គ្នាអានឹងយើងមិនដឹង តែបើថាឲ្យចិត្តអាក្រក់ដូចគ្មានទេ គ្មានអ្នកណាចិត្តអាក្រក់ផង ព្រោះយើងហែលប្រលូកអស់ហើយដូចគ្នាអស់ហើយ ។

ឈុនលី ៖ យូរៗទៅស្រឡាញ់គ្នាដូចបងប្អូនចឹងទៅ?

ធួក ៖ មានអីធម្មតា ។

ឈុនលី ៖ ចឹងបើសិនឥឡូវឲ្យអ៊ំទៅនៅខាងក្នុងវិញ ក៏អត់ចេះនៅដែរចឹង?

ធួក ៖ ចេះប៉ុនឲ្យតែដូចថា ។

ឈុនលី ៖ ឲ្យមានមុខរបរ?

ធួក ៖ ឲ្យតែមានមុខរបរ ចេះនៅ ។

ឈុនលី ៖ ចុះរហូតមកដល់ឥឡូវ អ៊ំចង់ទៅនៅក្នុងអត់?

ធួក ៖ ចង់ចេះចង់ហើយ តែវាដូចថាបើយើងទៅដោយថាមានទឹកទន្លេងដូចថាដីនឹងគេលក់ ប៉ុក៏យើងអាចនៅបានស្រែ មានស្រែមានអីយើងចេះចង់នៅហើយ ។ តែដល់ពេលយើងទៅនៅឈើៗចឹងវាដូចថាយើងខ្លាចលក់ពីត្រង់នេះទៅនៅត្រង់នោះ ខ្លាចវា ។

ឈុនលី ៖ វាអត់បានអី ខ្លាចវាអត់បានអី?

ធួក ៖ ខ្លាចវាអត់បានអី ហើយម្យ៉ាងរបស់វាឥឡូវវាថ្លៃណាស់ ដល់ហើយយើងមានចំការមានស្រែ យើងចេះទ្រាំនៅនឹងទៅណា តែបើកាលលើកមុនគេផ្អើលគេភ័យចង់ទៅដែរ ។

ឈុនលី ៖ គេផ្អើលពេលណា?

ធួក ៖ ទេ! បើសិនណាសភាពការណ៍ចេះចុះអានឹងដូចថាយើងមានផ្ទះហើយចឹង តែវាមិនទាន់ត្រូវគ្នា ។ រៀបចំអីវ៉ាន់ទៅហើយតើ ថ្ងៃមុននោះ ថ្ងៃមុនអីព្រះវិហារនេះ ជិតនេះព្រះវិហារនេះ

ឈុនលី ៖ ឆ្នាំមុនអី ប៉ុន្មានខែមុននេះដែរ?

ធួក ៖ ទេ! ដែលផ្អើលក្រែងពីប៉ោយប៉ែតអី ឡើងរកផ្លូវចេញមិនឃើញនឹង រៀបចំអីវ៉ាន់ដែរ ។

ឈុនលី ៖ ដូចដើមឆ្នាំ?

ធួក ៖ អឺ! រៀបចំអីវ៉ាន់ដាក់គោយន្តអស់ហើយ កូនចៅអីគេ ។

ឈុនលី ៖ រៀបដាក់គោយន្ត?

ធួក ៖ ដាក់គោយន្តប្រុងទៅនោះ ។

ឈុនលី ៖ ទៅនឹងប្រុងទៅណា?

ធួក ៖ ប្រុងទៅនឹងទៅដូចថាយើងមានបងប្អូននៅកូនដំរីចឹង យើងឈប់សម្រាកនឹងសិន ។

ឈុនលី ៖ ដាក់អង្ករ ដាក់ឆ្នាំង?

ធួក ៖ អឺ! បើថាគេដេញខ្លាំងទៅទៀត ចេះតែទៅនឹងគេទៅ ។

ឈុនលី ៖ ហើយអ្នកស្រុកនឹងគេរៀបចំដូចគ្នា?

ធួក ៖ រៀបចំដូចគ្នា អាខ្លះចេញទៅផ្អើលផ្លូវចេញអត់រួច អាខ្លះចេញទៅខាងនោះ ។

ឈុនលី ៖ ហេតុអីបានចេញអត់រួច?

ធួក ៖ វាច្រើន មនុស្សវាច្រើនចង្អៀតគ្នា ។

ឈុនលី ៖ ចឹងមិនស្រុះ ពេលនឹងម៉ាសារទៀត?

ធួក ៖ អឺ! អ្នកខ្លះចេញទៅ អ្នកខ្លះថាទៅមិនរួចទេ នៅគោយន្តនៅស្អីនោះ ។

ឈុនលី ៖ ឡានឡើងថ្ងៃផង?

ធួក ៖ ហ្នឹងហើយ ។ កាលនោះអាត្រាក់ផ្ទះគេខាងនោះ គេឲ្យកូនអ៊ំបើកអាត្រាក់ ដល់ចឹងគេយកមកទុកមក អាត្រាក់គេមាន២ អ៊ំគ្មានអីទេ មានតែគោយន្តមួយ ។

ឈុនលី ៖ នៅណាវិញចំការ?

ធួក ៖ នៅក្បាលហុង ។

ឈុនលី ៖ អានឹងនៅណា នៅជិតភ្នំ?

ធួក ៖ នៅហួសភ្នំនេះទៀត ។

ឈុនលី ៖ ភ្នំអីគេ?

ធួក ៖ ភ្នំម៉ាឡៃ ។

ឈុនលី ៖ នៅហួសភ្នំម៉ាឡៃ ដីធំដែលចំការ?

ធួក ៖ ភ្នំធំ ។

ឈុនលី ៖ ប៉ុន្មានហិចតា?

ធួក ៖ ប្រហែលជា៧០រ៉ៃ ។

ឈុនលី ៖ កាលនឹងធ្វើម៉េចបានចំការ គេចែកឲ្យ?

ធួក ៖ អត់ទេ គេថាគេចែកក៏ថាបាន ដូចថាយើងស្គាល់គ្នាជិតៗចឹងទៅ ចេះតែបបួលគ្នាចាប់ចំការចាប់អីចឹង អ្នកណាក៏ដូចគ្នាចឹងដែរ ។ ទៅអាចថាស្រឡាញ់ត្រង់ណា ស្រឡាញ់ត្រង់នេះបោះបង់គោលឲ្យចឹងទៅ ។

ឈុនលី ៖ ចឹងអ្នកណាចាប់បានចាប់ទៅ ។ ប៉ុន្តែចាប់ដីបូងព្រៃ ឬមួយក៏?

ធួក ៖ ព្រៃ មើលគ្នាមិនឃើញ ព្រៃមើលគ្នាសឹងថាមើលគ្នាពីនេះទៅដល់មើលមិនឃើញ មើលគ្នាមិនឃើញទេ ។

ឈុនលី ៖ ហើយយើងកាប់ឆ្ការទៅ?

ធួក ៖ កាប់ ។

ឈុនលី ៖ ចុះព្រៃធំៗហើយធ្វើម៉េចទៅ កាប់យកទៅណាវិញ?

ធួក ៖ មុនដំបូងនោះ មុនដំបូងយើងជួលគេមកកាប់ ម៉ាវ៉ៃដូចថាគេនិយាយលាសជើងក្រោម យើងនិយាយថាលាសជើងក្រោម ។

ឈុនលី ៖ ចាំ! កាប់អាព្រៃតូចៗ?

ធួក ៖ យើងជួលគេវ៉ៃ៣០០ ចង់ការគេដូចថា១ម៉ឺនចឹង ដល់ពេលគ្រប់ម៉ាឆ្នាំនឹង យើងនិយាយថា ១០ខែ ឬ១២ខែ គេយក៥០០០ ដូចថាអ៊ីចឹង អត់មានចឹងទៅចង់ការគេ១ម៉ឺនចឹងយកមកទ្រួសជើងក្រោមហើយ ទ្រួសបានប្រហែលជា១០វ៉ៃចឹងទៅ បានម៉ាស៊ីននឹងអន្ទង់ៗអាធំៗសន្កត់ ដុតទៅឆេះអាណានៅដុំធំតូចនឹង យើងប្រមូលដុតម៉ាសារទៀត ។ ដល់តែពេលធ្វើបាន១ម៉ឺនជួនកាលធ្វើបានក្នុង១ម៉ឺននឹងបានថ្លៃការគេទេ ហើយរាយដីគេទេ គ្មានបានចាយអីទេ អាលុយ១ម៉ឺននឹង បានយកមកធ្វើជួលគេកាប់ជួលគេវ៉ៃជួលគេដាំ ដល់ពេលឡើងឲ្យគេ ១ម៉ឺននឹងឡើងគេ៥០០០ ឬ៤០០០ ហើយចឹងបានវាលដី តែប៉ុននឹងឯង ។

ឈុនលី ៖ តែឈើនឹងយកទៅណា?

ធួក ៖ ដូចអ្នកណាដែលធំៗអារអុស ទិញបានខ្លះ ។

ឈុនលី ៖ ធ្វើផ្ទះ?

ធួក ៖ ហ្នឹងហើយ ខ្លះទៅដែលដឹកទៅ ។

ឈុនលី ៖ ដើមធំៗទេ ដើមព្រៃ?

ធួក ៖ .......... ។

ឈុនលី ៖ ប៉ុនណា?

ធួក ៖ ប៉ុននេះ បើអាធំនេះប៉ុនពាងនេះ ឬក៏តូចជាងពាងនេះ អានឹងភាគច្រើនគេអារមិនសូវបានអ្នកណាយកមកធ្វើផ្ទះទេ ច្រើនលក់ទៅថៃអស់ ពីព្រោះពេលដែលយើងអារឈើល្អ គឺយើងអត់ត្រូវគ្នា ។ ដល់ពេលម៉ាវគ្គក្រោយ អាឈើល្អវាអស់ហើយ យើងយកអាឈើតូចៗយើងត្រូវគ្នា យកអាឈើតូចៗនឹងមកធ្វើផ្ទះ ។

ឈុនលី ៖ ចឹងអ្នកណាចាប់បានប៉ុនណា លក់ខ្លួនឯង លក់រៀងខ្លួន ដូចថាអ្នកណាចាប់ដីបានប៉ុនណា យើងកាប់ព្រៃចឹងទៅ ហើយអាព្រៃធំៗយើងយកលក់យកលុយខ្លួនឯងទៅ ។ ក្រោយមកយើងធ្វើចំការអីចឹង?

ធួក ៖ ហ្នឹងហើយ យើងលក់តែស្រេចចិត្តយើង យើងធ្វើយើងលក់ទៅអត់អីទេ ។

ឈុនលី ៖ កាលនឹងឈើធំចឹង ដើមឈើអីគេទៅប៉ុនពាង?

ធួក ៖ គគីរ ។

ឈុនលី ៖ គគីរ មានបេងមានអីដែរ?

ធួក ៖ បេងមាន ។

ឈុនលី ៖ ហើយអ៊ំអត់ទុកបេងធ្វើផ្ទះធ្វើអីដែរ?

ធួក ៖ ដូចទុកម៉េច ភាគច្រើនគេលក់ និយាយទៅយើងអត់មានយើងដូចថាអត់មានធ្វើស្រែ ធ្វើភ្លឺ មានដើមឈើនឹង អាវទៅលក់ទៅទិញជួនកាលគេអត់បើកអង្ករឲ្យ ។ យើងលក់ទៅ យើងយកមកទិញអង្ករខ្លួនយើងដោះស្រាយ ។

ឈុនលី ៖ គេដឹងទេ អ្នកគ្រប់គ្រងនៅនឹង គេដឹងថាយើងដូចថាលក់អីចឹង?

ធួក ៖ ចេះតែដឹង ប៉ុនធម្មតាយើងមិនត្រូវគ្នាគេចេះតែអនុគ្រោះ បើមិនអនុគ្រោះ ។

ឈុនលី ៖ អ្នកចេះដឹងម៉េច?

ធួក ៖ ......ដូចតែគ្នាស៊ី ។

ឈុនលី ៖ ទាល់តែអ្នកធំហ៊ានបានអ្នកតូចទៅតាមក្រោយ?

ធួក ៖ ......អ្នកធំជាងយើង បើតិចមក ។

ឈុនលី ៖ អានឹងគេចាប់ផ្ដើមកាប់ឆ្ការនឹង ហើយចាប់ដីស្រែនឹងឆ្នាំណាទៅ?

ធួក ៖ ទេ! មិន...ប្រហែល៩៥ ៩៦ដឹងក្នុយនោះ ។

ឈុនលី ៖ ជិតសមាហរណកម្ម?

ធួក ៖ អឺ! ពីព្រោះយើង៩៣យើង ។

ឈុនលី ៖ អ៊ុនគាត់?

ធួក ៖ អឺ! .....អាច៩៥ ៩៦ហើយ ។

ឈុនលី ៖ ហើយអ៊ំបើនិយាយពីអ្នកជិតខាងវិញ បើសិនយើងគិតទៅសម័យនឹង ពេលមកនៅនឹងនេះ ហើយយើងនៅដូចថានៅរួមគ្នាចឹង ដូចបងប្អូនអីចឹង ដូចសម័យ៣ឆ្នាំនឹង ហើយរហូតមកដល់សម័យឥឡូវដូចថាមានអ្នកចំណូលថ្មីមកចឹង ហើយយើងរាប់អានគ្នាដូចពីមុនមើលទៅមួយណាជិតស្និតជាង?

ធួក ៖ និយាយថាពីមុនឬក៏ឥឡូវ?

ឈុនលី ៖ និយាយបើប្រៀបធៀបពីមុនមកដល់មកដល់សម័យឥឡូវ បើយើងប្រៀបធៀបថាសាច់ញាតិអ្នករាប់អានជិតខាង....?

ធួក ៖ សម័យមុនវាផ្សេង សម័យមុនយើងប្ដីទៅមុខអស់ចឹង យើងស្និតស្នាលជាង ដល់មកសម័យនេះយើងស្និតស្នាលដែល តែមិនដូចមុនទេ ពីព្រោះអីយើងចាយលុយ ។

ឈុនលី ៖ យើងរកឯកជន?

ធួក ៖ អឺ! ម្ល៉ះហើយគេខំរបស់គេ យើងក៏ប្រឹងរបស់យើងទៅ ពីព្រោះសម័យមុនអត់ចាយលុយ

ឈុនលី ៖ សម័យមុន...លុយ?

ធួក ៖ ហ្នឹងហើយ ចាយដែរតែយើងចាយវាដូចថាមិនទំនើប វាគ្មានកង់គ្មានម៉ូតូ ដល់ចឹងវាមានតែលុយចាយជាក់ហោប៉ៅ ប៉ុននឹងឯង ។ ដល់ឥឡូវវាមានឡានមានម៉ូតូចឹង ដល់ហើយការដែលយើងស្និតស្នាលនឹងវាស្និតដែរ ក៏ប៉ុន្តែក្នុងនឹងយើងវាដូចមិនស្និតស្នាលពេកទេណា អ្នកណាគេស្និតស្នាលក៏អានឹងជាធម្មតារបស់គេទៅ ពីព្រោះគេនៅស្និតស្នាលល្អគេនឹកឃើញសម័យនោះគេពិបាកអីចឹង ។ ហ៎! អ្នកខ្លះទៅក៏មិនដូចមុនទេ ពីព្រោះអីយើងវាចាយលុយនោះ ដល់ចឹងទោះបីខុសត្រូវគ្នាតិចតួច យើងខុសយើងមាត់ប្រកែកគ្នាឈ្លោះគ្នានោះ បើលើកមុនអត់សូវទេ ឥឡូវស្រុកវាគេចាយលុយ ។

ឈុនលី ៖ ចឹងអ៊ំបើគិតទៅនៅខាងនេះ ប៉ែកខាងដូចម្តុំអ៊ំនៅតាំងពីឆ្នាំ៧៩មក ចឹងកាលពីនោះមកសុទ្ធតែទ័ពនៅរហូតមកតំបន់នឹង?

ធួក ៖ អឺ! ជាប់រហូត ។

ឈុនលី ៖ អានឹងអាចថាតំបន់ជួរមុខអត់ អាម្តុំដែលអ៊ំនៅនឹង?

ធួក ៖ នៅណា?

ឈុនលី ៖ ពេលដែលអ៊ំនៅ៧៩នឹង នៅម្តុំអីគេកងតូច(គោកតូច)?

ធួក ៖ ៧៩នោះ ៧៩នៅឯនោះ នៅម៉ាជួរកូនដីរ៉ៃនោះ នឹងជួរមុខហើយ ប៉ុន្តែជួរមុខៗទៅចល័តទេ តែមានទ័ពគេការពារ ។

ឈុនលី ៖ នៅពីក្រោយវិញ?

ធួក ៖ គេមកខាងនេះព្រំដែន យើងទ័ព យើងចល័តមែនតែយើងបង្កបង្កើនផល តែអានឹងបើគេនិយាយទៅវានៅកៀកព្រំដែនដែរ ។

ឈុនលី ៖ យើងនៅដឹកជញ្ជូនផង ហើយយើងនៅបង្កបង្កើនផលសម្រាប់អ្នកនៅខាងក្រោយនេះដែរ អ្នកខាងព្រំដែននេះដែរ?

ធួក ៖ ហ្នឹងសម័យ៣ឆ្នាំ?

ឈុនលី ៖ ចា៎!

ធួក ៖ សម័យ៣ឆ្នាំយើងអត់មានដឹកជញ្ជូនអីទេ យើងគិតតែធ្វើស្រែ ទៅស្ទូងទៅដក ទូលកណ្តាប់ស្រូវស្រែប្រាំងប៉ុននឹងឯង យើងអត់មានដឹកជញ្ជូនអីទេ ពីព្រោះសម័យនឹងគេលែងសង្គ្រាមហើយ មិនចឹង ។

ឈុនលី ៖ ចា៎! ពេលនឹងគឺរស់នៅអីចឹងធម្មតា ។

ធួក ៖ ពេលនោះគឺខ្មែរក្រហមចូលមកហើយ មានសង្រ្គាមណាទៀត តែវានិយាយទៅវាវេទនាត្រង់នេះទៀត ពីព្រោះអីជួនកាលខ្លាច ពីព្រោះមិន..........។

ឈុនលី ៖ អ៊ឺដែលឬ ពេលនឹង?

ធួក ៖ ឬពីព្រោះអីជួនកាលអ្នកខ្លះជាប់ខ្សែយួនជីដូនជីតាយួន ជួនកាលគេតាមដានដឹងនឹងគេ.........យើងអ្នកល្អមិនដឹងថាខ្លួនយើងល្អអាក្រក់ទេ ភ័យណាស់ មិនដឹងថាអ្នកខ្លះ ដូចគ្មានកំហុសអីអ្នកស្អប់អីបងប្អូន......ក៏ខ្លាច អ្នកខ្លះរៀនថ្នាក់ខ្ពស់ក៏ខ្លាច អ្នកដែលរៀនថ្នាក់ខ្ពស់នឹង គេរៀនគ្រាន់បើអីនឹង គេយកទៅអស់ហើយ តែមិនដឹងថាគេយកទៅនឹង គេឲ្យនៅក្នុង ឬគេវៃចោលអីនឹងអ៊ឹអត់ដឹងទេ ។ ហើយនិយាយពីរឿងប្រវត្តិរូបធ្វើហើយធ្វើ ។

ឈុនលី ៖ ដូររហូត? ប៉ុន្មានខែគេដូរម្តង?

ធួក ៖ មិនដឹងទេ ប៉ុនធ្វើនោះធ្វើ ប្រវត្តិរូបល្អិតដូចថាមិនដឹងប៉ុន្មានខែប៉ុន្មានអី ប៉ុនខស្សាហ៍ធ្វើប្រវត្តិល្អមិនល្អ បើអ្នកណាមានអ្នកគេផ្សេងមានស្អីៗចឹង សួរថាផ្ទះនឹងមានស្អី មានគោប៉ុន្មាន ឬស្រែប៉ុន្មាន មានឡានមានស្អីចឹង បើយើងឆ្លើយត្រង់ទៅក៏មិនដឹងគេយកយើងទៅក៏មិនដឹងជួនកាល.........ខ្លាចរហូតកាលនឹងខ្លាចណាស់ ។ សូម្បីតែយើងអ្នកក្រនឹងក៏ចង់ខ្លាចដែរ ពីព្រោះ...........................ដឹងថាអ្នកក្រនឹងជួនកាលវាមិនដឹងថាខុសស្អីយើងមិនដឹងដែរ ពីព្រោះអ្នកក្រក៏ទៅដែរ ពីព្រោះសម័យនឹងអ្នកក្រធ្វើទាហានច្រើនជាងគេ ។

ឈុនលី ៖ ចា៎!

ធួក ៖ ដល់ពេលគេរើសបងប្អូនធ្វើទាហានមិនជាប់ អ្នកក្រនឹងក៏ខ្លាំង ។

ឈុនលី ៖ អ្នកមានភាគច្រើនគេឲ្យទៅធ្វើស្រែ មានដឹងអត់?

ធួក ៖ ..........យើងមិនសូវដឹងទេ ប៉ុនយើងមិនសូវកំប៉េចកំប៉ុង ពីព្រោះអីយើងអ្នកណាមានក៏មានអ្នកណាធ្វើអីធ្វើទៅមិនរវល់ ពីព្រោះយើងដឹងថារបបនឹងវាកាចសាហាវដែរ អ្នកខ្លះទៅមិនល្អ គេរប៉េចរប៉ុចចឹងណា ។ ដូចយើងដឹងហើយ...............ហូបគេឲ្យហូបជុំគ្នា គេឲ្យហូបរួម គិចថាទៅធ្វើការរេះ យើងរើសក្តាមខ្យងហូបតែឯង ចង់ហូបតែឯងឃ្លានអីតែឯងដូចថាយើងស៊ីបាយឯង អត់បានទេ គេកសាងយើង គេណែនាំយើង ទាល់តែយើងបានមកយកមកដាក់រួមទៅ ។ រួចដូចថាម៉ាក្រុម១០នាក់ចឹង យើងយកមកឆ្អិន ដូចថាក្តាមម៉ាចានចឹង យើងយកមកស្ងោររួចហើយយើងហូបជុំគ្នា កុំឲ្យហូបតែឯងៗគេណែនាំយើងហើយ ។

ឈុនលី ៖ ឯងខំរកសោះនឹង ។

ធួក ៖ ហើយបត់ជើងបត់ដៃនឹងយើងសុំគេដែរ មិនមែនចង់ថាអូ! ពេលស្ងួតពេកដកចេះតិចថាចង់ទៅបត់ជើងចេះដើររុយអត់បានទេ ប្រាប់គេ ។

ឈុនលី ៖ ចុះបើសិនគេនៅឆ្ងាយយើងមិនរត់ទៅប្រាប់សិន?

ធួក ៖ ឧបមាថាទៅស្ទួងជុំគ្នាចឹង ចាប់ពីបើយើងនិយាយចាប់ពីព្រំរបងនឹងមកចុះ ព្រំរបងផ្ទះនោះ ហើយគេមានមេកងតូចកងធំចឹង ធម្មតាយើងស្ទួង......យើងប្រាប់ទៅមេក្រុមយើង....... ។

ឈុនលី ៖ អ្នកខ្លះរត់ទៅអត់ទាន់?

ធួក ៖ អ្នកខ្លះគេតាមដាន អត់មានរត់ទេ រត់ទៅណាអត់រួចទេ អត់រួចទេ មិនបាច់រត់ទេ បើរត់ៗ តែ គេតាមគេដូចថាគេ បើថាត្រឹមនារីចល័តអីគ្មានអ្នកណារត់ទេ រត់ទៅណារួចអត់រត់ទេ ។

ឈុនលី ៖ បើគិតទៅកងចល័តអីចឹងមានច្រើនកង?

ធួក ៖ មានច្រើន ។

ឈុនលី ៖ កងអ៊ំ៣០នាក់?

ធួក ៖ ម៉ាកងវរៈយើងមាន៣កងធំ ម៉ាកងធំមាន៣០នាក់ ហឺ! ម៉ាកងតូចមាន៣០នាក់ ម៉ាក្រុមមាន១០ ៗ ម៉ាកងតូចវាមាន៣០ ម៉ាកងធំវាមាន៩០ទៅ១០០ ដល់ម៉ាកងវរៈវាមាន៣០០ជាង ។ ឥឡូវវាឈប់មានកងវរៈឈប់អីចឹងវាស្ងួងវាវង្វេងអស់ហើយ បើលើកមុនសម័យនឹងគេប្រើចឹង យើងចាំតែចឹងឯង ។ ដល់មកឥឡូវយើងវាឈប់ប្រើចឹង យើងអត់សូវចាំដែរ ។

ឈុនលី ៖ ចុះអ៊ំបើគិតទៅម៉ាប៉ែកចាប់ពីតំបន់ដែលអ៊ំនៅ..................... បើគិតមកប៉ែកខាងនេះតាំងពីទីតាំង...................តំបន់ទីប៉ុន្មានៗ?

ធួក ៖ ចឹង ទេ! អ៊ំក៏មិនដឹង ។

ឈុនលី ៖ បើភូមិភាគអីក៏អត់ដឹងដែរ?

ធួក ៖ គេហៅចេះទៅ តែយើងមិនបានយកចិត្តទុកដាក់ ពីព្រោះអីយើងវាមិនបានគិតគូររឿងចឹងទេ គេហៅតំបន់ប៉ុន្មានតំបន់៣ ។

ឈុនលី ៖ តំបន់៣?

ធួក ៖ អឺ! ចុះខាងនេះតំបន់ប៉ុន្មាន រឿងតំបន់អីយើងមិនសូវដឹង ពីព្រោះអីយើងសម័យនោះអត់សូវប្រើតំបន់ទេ យើងដឹងថាស្រុកនិមិត្ត ភូមិគោកធំគោកតូច យើងដឹងតែនឹងដល់សម័យនឹងគេភូមិភាគ១ ភូមិភាគ៣ អីណាតំបន់១តំបន់២យើងអត់ ហើយយើងក៏មិនបានគិតគូរឿងចឹងដែរ ពីព្រោះយើងអត់មានធ្វើការផង យាមកូនគេនោះ យាមចល័តនោះ អ្នកណាថាតំបន់ប៉ុន្មានក៏មិនសូវយកចិត្តទុកដាក់ ។ គេថាពាយ័ព្យ ដឹងថាខាងនឹងពាយ័ព្យ ។

ឈុនលី ៖ ដឹងខាងពាយ័ព្យ?

ធួក ៖ អឺ! ដឹងពាយ័ព្យ តែត្រង់ថាតំបន់ប៉ុន្មានក៏មិនសូវយកចិត្តទុកដាក់ ដឹងថាអូ!ស្វាយ មង្គលបូរី បាត់ដំបងចឹងវិញ ។

ឈុនលី ៖ ចុះអ៊ំគ្រួសារអ៊ំទៅណា?

ធួក ៖ ទៅដឹកថ្ម ។

ឈុនលី ៖ ជាមួយកូនជាមួយអី?

ធួក ៖ កូនអ្នកទៅទម្លាក់ថ្ម មិនធ្វើអីចឹង ។

ឈុនលី ៖ ចំការនឹងដាំអីគេ?

ធួក ៖ ចំការដាំពោត ។

ឈុនលី ៖ បានផល?

ធួក ៖ ពោតដាំចុងដៃ ដល់ពេលចឹងទៅ....... ។

ឈុនលី ៖ ខ្ញុំសួរអ៊ំយូរហើយ ហើយមានអីសួរខ្ញុំ?

ធួក ៖ អឺ!

ឈុនលី ៖ ចង់ដឹងអីពីខ្ញុំវិញខ្លះ?

ធួក ៖ មិនដឹងសួរម៉េចទេក្មួយអើយ អ៊ំមិនសូវចេះនិយាយ ។

ឈុនលី ៖ ចុះអ៊ំមានសល់រូបថតចាស់ៗដែរ កាលជំនាន់នឹងមក?

ធួក ៖ មានសល់ដែរ ប៉ុនថាយើងដូចថាសល់ទុកបងប្អូនឯងស្រុក ។

ឈុនលី ៖ រូបថតដូចកាលពេលអ៊ំមកនៅនេះ?

ធួក ៖ ពីសម័យ៣ឆ្នាំៗគ្មានអ្នកណាបានថតបានអីទេ ។

ឈុនលី ៖ ក្រោយ៣ឆ្នាំមក ពេលដែលយើងចេញមកនេះ?

ធួក ៖ អត់ទេ ។

ឈុនលី ៖ អត់មានផង?

ធួក ៖ អឺ!

ឈុនលី ៖ ស្តាយ ។

«ចប់»